ព្រះវិន័យ

# បាតិមោក្ខសំវរសីលសង្ខេប

និង

# ខន្ធកវិន័យសង្ខេប

**ព្រះគ្រូសង្ឃសត្ថា ជួន - ណាត**

អាចារ្យបង្រៀនសាលាបាលីជាន់ខ្ពស់

និង

**ព្រះញាណបវរវិជ្ជា ល្វី - អែម**

ចាងហ្វាងសាលាបាលីជាន់ខ្ពស់ រៀបរៀង

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំពីរគណៈបានអនុញ្ញាតហើយ

បោះពុម្ពលើកទី១០

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥១៤

WAT KHEMARARATANARAM

ទំព័រនេះ ទទេ

# បញ្ជីមាតិការ


| មាតិកា | ទំព័រ | បន្ទាត់ |
|---|---|---|
| អនុសាសនៈ ៨ យ៉ាង.......................................... | ០៩ | ០១ |
| ត្រៃសិក្ខា.......................................................... | ១០ | ០១ |
| អាបត្តិ............................................................... | ១០ | ០៧ |
| អាបត្តាបជ្ជនាការ............................ .................. | ១១ | ០១ |
| សិក្ខាបទ........................................ .................. | ១១ | ០៩ |

## បាតិមោក្ខសំវរសីល

| | | |
|---|---|---|
| បារាជិក៤.......................................................... | ១២ | ០២ |
| សង្ឃាទិសេស១៣................................................ | ១២ | ០៩ |
| អនិយតៈ២.......................................................... | ១៥ | ១៣ |

## និស្សគ្គិយបាចិត្តិយ ៣០

| | | |
|---|---|---|
| ចីវរវគ្គទី១....................................................... | ១៦ | ១៤ |
| កោសិយវគ្គទី២................................................... | ២០ | ១១ |
| បត្តវគ្គទី៣....................................................... | ២៣ | ០១ |

## សុទ្ធិកបាចិត្តិយ ៩២

| | | |
|---|---|---|
| មុសាវាទវគ្គទី១ ................................................ | ២៦ | ១៤ |
| ភូតគាមវគ្គទី២ ............................... .................. | ២៨ | ០៦ |
| ឱវាទវគ្គទី៣ ..................................... ................. | ៣០ | ១៣ |

| មាតិកា | ទំព័រ | បន្ទាត់ |
|---|---|---|
| ភោជនវគ្គទី៤ ..................................................... | ៣២ | ១០ |
| អចេលកវគ្គទី៥ ................................................... | ៣៦ | ០១ |
| សុរាបានវគ្គទី៦ .................................................. | ៣៨ | ០៩ |
| សប្បាណកវគ្គទី៧ ................................................ | ៤០ | ១០ |
| សហធម្មិកវគ្គទី៨ ................................................ | ៤៣ | ០៣ |
| រាជវគ្គទី៩ .......................................................... | ៤៦ | ០៦ |
| បាដិទេសនីយៈ ៤ ......................................... | ៤៩ | ០៧ |
| សារូបទី ១ ......................................................... | ៥១ | ០១ |
| ភោជនប្បដិសំយុត្តទី ២ ........................................ | ៥៣ | ០១ |
| ធម្មទេសនាបដិសំយុត្តទី ៣ ................................... | ៥៦ | ០៧ |
| បកិណ្ណកៈទី ៤ ...................................................... | ៥៨ | ០១ |
| អធិករណ៍ ៤ ......................................................... | ៥៨ | ១៣ |
| អធិករណសមថ ................................................... | ៥៩ | ០៥ |


## សិក្ខាបទដែលមិនមានក្នុងបាតិមោក្ខ


| | | |
|---|---|---|
| ថុល្លច្ច័យ ........................................................... | ៦៥ | ០២ |
| ទុក្កដ ................................................................. | ៦៦ | ០១ |
| ទុព្ភាសិត ............................................................ | ៧២ | ១០ |
| ឧប្បត្តិហេតុនៃភិក្ខុនី ............................................ | ៧៣ | ១១ |
| បំណួនសិក្ខាបទនៃភិក្ខុនី ......................................... | ៧៦ | ១០ |
| ខន្ធកៈ ២២ .......................................................... | ៧៧ | ០១ |
| វារៈ ១៦ ............................................................. | ៨៤ | ០១ |
| វត ១០ ប្រការ ...................................................... | ៨៧ | ០១ |

# ឧបន្យាសកថា

ព្រះវិន័យបាតិមោក្ខសំវរសីលសង្ខេបនេះ ខ្ញុំបានរៀបរៀងហើយជាស្រេច តាំងពីឆ្នាំមមីសំរឹទ្ធិស័កពុទ្ធសករាជ ២៤៦១ គ្រិស្តសករាជ ១៩១៨ ហើយបានប្រគេនព្រះតេជព្រះគុណព្រះមហាវិមលធម្ម ឆាម **ថាខ** បាងហ្វាងសាលាបាលី សូមឱ្យលោកផ្ទៀងផ្ទាត់ឱ្យ លោកក៏បានផ្ទៀងផ្ទាត់ យល់ឃើញថា ត្រឹមត្រូវហើយ តែមិនទាន់បានសម្រេច ទៅជាសៀវភៅបោះពុម្ពនៅឡើយ ។

ដែលខ្ញុំរៀបរៀងវិន័យនេះ ខ្ញុំនិងបានប្រែបេញ ពីបាលីអដ្ឋកថាដីកា នៃវិនយបិដក ដោយស្នាដៃរបស់ខ្ញុំទាំងអស់ក៏ទេ កាលដែលរៀបរៀងនោះ ខ្ញុំបានយកវិន័យបាតិមោក្ខសំវរសីលសម្រាយច្រើនច្បាប់ ដែលជាស្នាដៃរបស់លោកអ្នកប្រាជ្ញក្នុងកម្ពុជប្រទេសយើងនេះខ្លះ ក្នុងស្យាមប្រទេសខ្លះ ទាំងសម័យមុននិងសម័យក្រោយមកជាបែប ហើយខ្ញុំបានយកគម្ពីរ

វិនយបិដកគឺគម្ពីរអាទិកម្ម និងបាចិត្តិយបាលី និងគម្ពីរបឋម-សមន្តបាសាទិកា និងទុតិយសមន្តបាសាទិកា អដ្ឋកថា ព្រម ទាំងដីកា នៃគម្ពីរទាំងនោះ មកមើលពិនិត្យធៀបសេចក្ដីគ្នា ហើយទើបរៀបរៀងឱ្យកើតជាវិន័យនេះឡើង ។

វិន័យនេះ ខ្ញុំរៀបរៀងជាសេចក្ដីសង្ខេបទាំងឃ្លាល្បះក៏ដក លៃឱ្យល្មម ស្រួលទន្ទេញស្រួលសូត្រ ព្រោះមិនមែនជាវិន័យ សម្រាប់មើលត្រួសៗ ហើយលែងមើលនោះទេ ជាវិន័យ-សម្រាប់ទន្ទេញឱ្យចាំសូត្រមាត់ទទេបាន សម្រាប់នវកភិក្ខុ គឺភិក្ខុ ដែលទើបបានឧបសម្បទាថ្មី សិក្សា, ដោយគំនិតខ្ញុំយល់ថា បើបានទន្ទេញចាំមាត់ហើយ ជាប្រយោជន៍នឹងនាំឱ្យភិក្ខុ អ្នក បានទន្ទេញចាំមាត់ហើយនោះ ពេញចិត្តនឹងវិន័យ ស្រឡាញ់ វិន័យ បេះសាកសួរ បេះពិគ្រោះឬបេះស្ដាប់សេចក្ដីអធិប្បាយ ក្នុងសំណាក់លោកដែលជាឧបជ្ឈាយ៍ ឬអាចារ្យរបស់ខ្លួន ឬ ក៏បេះសាកសួរសភាគភិក្ខុផងគ្នា, ភិក្ខុណាដែលបានរៀនវិន័យ បេះដឹងច្រើនជាងខ្លួន, ពុំនោះនឹងខំប្រឹងមើលវិន័យវិនិច្ឆ័យពិស្ដារ

តទៅទៀត ក៏នឹងអាចចូលចិត្តសេចក្ដីត្រង់ណា ដែលខ្លួនធ្លាប់សង្ស័យនោះ ដោយច្បាស់លាស់ឡើង ហើយក៏នឹងទៅជាអ្នកបេះវិន័យស្ទាត់ជំនាញឡើងបាន ។

លុះមកដល់ឆ្នាំវកទោស័កពុទ្ធសករាជ ២៤៦៣ គ្រិស្ត-សករាជ ១៩២០ លោកគ្រូព្រះញាណបវរវិជ្ជា អែម ចៅ-អធិការវត្តលង្កា អាចារ្យបង្រៀន នៅសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ កាលលោក មិនទាន់ធ្វើជាចាងហ្វាងនៅឡើយ លោកមានសេចក្ដីពេញចិត្ត នឹងវិន័យនេះ ហើយលោកបានបញ្ចូលសិក្ខាបទទាំងឡាយ ដែលមិនមានក្នុងបាតិមោក្ខ ព្រមទាំងរបៀបខន្ធកវិន័យជាសេចក្ដីសង្ខេប ដែលលោកបានចាត់រៀបរៀងហើយនោះ មករៀបរៀងខាងចុងជាលំដាប់បន្ទាប់ តអំពីបាតិមោក្ខសំវរសីលនេះ រួមឱ្យទៅជាសៀវភៅមួយសម្រាប់ឱ្យនវកភិក្ខុទាំងឡាយ សិក្សាតអំពីបាតិមោក្ខសំវរសីលទៅ ។ ឥឡូវនេះ ខ្ញុំក៏ទុកឱ្យនៅតាមរបៀបនោះទាំងអស់ ព្រោះខ្ញុំយល់

ដូចគំនិតលោកគ្រូព្រះញាណបវរវិជ្ជា ដែលលោកបានរៀប

រៀងថែមឡើងទៀតនោះដែរ ដើម្បីជាផ្លូវបម្រើនសេចក្ដីបេះដឹង

ដល់នវកភិក្ខុទាំងឡាយ ក្នុងពុទ្ធសាសនមណ្ឌលតរៀងទៅ ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

នៅថ្ងៃចន្ទ ២ កើត ខែភទ្របទ ឆ្នាំថោះនព្វស័ក ពុទ្ធសករាជ ២៤៧០

ត្រូវនិងថ្ងៃ ២៩ ខែអាសាធ ឆ្នាំ ១៩២៧

**ព្រះសាសនសោភ័ណ ជោតញ្ញាណោ ជ.ណាត**

បាងហ្វាងរងសាលាបាលីជាន់ខ្ពស់

WAT KHEMARARATANARAM

# អនុសាសនៈ

ពាក្យប្រៀនប្រដៅដែលព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតឱ្យភិក្ខុជាឧបជ្ឈាយ៍ ប្រៀនប្រដៅកុលបុត្រ ដែលទើបបានឧបសម្បទាថ្មីៗ ក្នុងពេលជាលំដាប់បន្ទាប់អំពីញត្តិចតុត្ថកម្មវាចា ដើម្បីឱ្យភិក្ខុថ្មីនោះ បានចេះដឹងបណ្តើរជាការបណ្តោះអាសន្ន ហៅថា អនុសាសនៈ ។ នោះមាន ៨ យ៉ាង គឺ និស្ស័យ ៤ អករណីយកិច្ច ៤។

បច្ច័យជាគ្រឿងអាស្រ័យរបស់បព្វជិត ហៅថា និស្ស័យ មាន ៤ យ៉ាង គឺ ដើរបិណ្ឌបាត ១ ស្លៀកដណ្តប់សំពត់បង្សុកូល ១ នៅអាស្រ័យក្រោមម្លប់ឈើ ១ ឆាន់ថ្នាំដែលត្រាំដោយទឹកមូត្រ ១ ។

កិច្ចដែលបព្វជិតមិនត្រូវធ្វើ ហៅថា អករណីយកិច្ចមាន ៤ យ៉ាងគឺ សេពមេថុន ១ លួចទ្រព្យគេ ១ សម្លាប់សត្វ ១ ពោលអួតគុណវិសេសដែលមិនមានក្នុងខ្លួន ១ ។

# ត្រៃសិក្ខា

គុណជាតិដែលបព្វជិតត្រូវសិក្សា ហៅថា សិក្ខា មាន ៣ យ៉ាងគឺ សីល ១ សមាធិ ១ បញ្ញា ១ ។

សេចក្ដីសង្រួមកាយវាចាដោយប្រពៃ ហៅថា សីល ។ សេចក្ដីរក្សាចិត្តឱ្យស្ងប់រម្ងាប់ហៅថា សមាធិ ។ សេចក្ដីដឹងច្បាស់ក្នុងកងសង្ខារ ហៅថា បញ្ញា ។

# អាបត្តិ

ទោសដែលកើតឡើងព្រោះសេចក្ដីល្មើស នឹងវិនយប្បញ្ញត្តិដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាម ហៅថា អាបត្តិ ៗ នោះ ពោលដោយឈ្មោះមាន ៧ គឺ បារាជិក ១, សង្ឃាទិសេស ១, ថុល្ល-ច្ច័យ ១, បាចិត្តិយៈ ១, បាដិទេសនីយៈ ១, ទុក្កដ ១, ទុព្ភាសិត ១ ។

បារាជិកនោះ តែភិក្ខុត្រូវហើយ ក៏ដាច់បាកភិក្ខុភាវៈ ។ សង្ឃាទិសេសនោះ បើភិក្ខុត្រូវហើយ ត្រូវចូលបរិវាសកម្មទើបរួចចាកអាបត្តិបាន ។ អាបត្តិទាំង ៥ យ៉ាងនោះ បើភិក្ខុត្រូវហើយ ត្រូវសម្ដែងចំពោះមុខ សង្ឃ ឬគណៈ ឬបុគ្គល ទើបរួចចាកទោសបាន ។

## អាបត្តាបជ្ជនាការ

អាការៈ ដែលភិក្ខុនឹងត្រូវអាបត្តិទាំងនោះ មាន ៦ យ៉ាងគឺ **អលជ្ជិតា** ត្រូវដោយមិនមានខ្មាស ១, **អញ្ញាណតា** ត្រូវដោយមិនស្គាល់អាបត្តិ, គឺមិនដឹងថាធ្វើយ៉ាងនេះយ៉ាងនោះត្រូវអាបត្តិ ១, **កុក្កុច្ចប្បកតត្តា** ត្រូវដោយសង្ស័យហើយបេះតែធ្វើ ១, **អកប្បិយេ កប្បិយ សញ្ញិតា** ត្រូវដោយសម្គាល់ថាគួរក្នុងរបស់ដែលមិនគួរ ១, **កប្បិយេ អកប្បិយសញ្ញិតា** ត្រូវដោយសម្គាល់ថា មិនគួរក្នុងរបស់ដែលគួរ ១, **សតិសម្មោសា** ត្រូវដោយភ្លេចស្មារតី ១ ។

## សិក្ខាបទ

វិនយប្បញ្ញត្តិដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាម លើកឡើងជាប្រការមួយៗ ដែលហៅថាសិក្ខាបទនោះ មានក្នុងបាតិមោក្ខខ្លះ មិនមានក្នុងបាតិមោក្ខខ្លះ សិក្ខាបទដែលមានក្នុងបាតិមោក្ខនោះគឺ បារាជិក ៤, សង្ឃាទិសេស ១៣, អនិយតៈ ២, និស្សគ្គិយ-បាចិត្តិយ ៣០, សុទ្ធិកបាចិត្តយៈ ៩២, បាដិទេសនីយៈ ៤, សេក្ខិយវត្ត ៧៥ រួមជា ២២០ រាប់អធិករណសមថៈ ៧ ផ្សំផងជា ២២៧ ។

# បាតិមោក្ខសំវរសីល

## បារាជិក ៤

១- **មេថុនធម្ម:** ភិក្ខុសេពមេថុនធម្ម ត្រូវបារាជិក ។

២- **អទិន្នាទាន:** ភិក្ខុលួចទ្រព្យគេ ដោយយ៉ាងតិចបំផុត តាំងពីត្រឹមតម្លៃ ៥ មាសកឡើងទៅ ត្រូវបារាជិក ។

៣- **មនុស្សវិគ្គហ:** ភិក្ខុក្លែងសម្លាប់មនុស្ស ត្រូវបារាជិក ។

៤- **ឧត្តរិមនុស្សធម្ម:** ភិក្ខុពោលអួតឧត្តរិមនុស្សធម្ម គឺធម៌របស់មនុស្សក្រៃលែង ដែលមិនមានក្នុងខ្លួន ត្រូវបារាជិក ។

## សង្ឃាទិសេស ១៣

១- **សុក្កវិស្សដ្ឋិ** ភិក្ខុក្លែងធ្វើឱ្យទឹកសុក្កៈកម្រើកឃ្លាតបាកទី ត្រូវសង្ឃាទិសេស ។

២- **កាយសំសគ្គ** ភិក្ខុមានតម្រេក ចាប់ពាល់ត្រូវកាយស្ត្រីត្រូវសង្ឃាទិសេស ។

៣- **ទុដ្ឋុល្លវាច** ភិក្ខុមានតម្រេក និយាយពាក្យអាក្រក់ បំពោះទ្វារមគ្គនឹងស្ត្រី ត្រូវសង្ឃាទិសេស ។

៤- **អត្តកាមបារិចរិយ** ភិក្ខុមានតម្រេក និយាយល្បួងស្ត្រីឱ្យបម្រើខ្លួនដោយកាម ត្រូវសង្ឃាទិសេស ។

៥- **សញ្ចរិត្ត** ភិក្ខុនិយាយដឹកនាំឱ្យបុរស និងស្ត្រីបានគ្នាជាប្តីប្រពន្ធ ត្រូវសង្ឃាទិសេស ។

៦- **សញ្ញាចិក** ភិក្ខុធ្វើកុដិប្ញកដោយកំបោរឬដីស្អិត មិនមានអ្នកណា ១ ជាម្ចាស់របស់, បំពោះជាទីនៅរបស់ខ្លួន, ត្រូវធ្វើឱ្យត្រូវនឹងប្រមាណ ប្រមាណនោះគឺ បណ្តោយ ១២ បំអាម ទទឹង ៧ បំអាម ដោយបំអាមព្រះសុគត, កាលដែលនឹងធ្វើនោះ ត្រូវឱ្យសង្ឃសម្តែងទី ឱ្យមុនហើយសឹមធ្វើ, បើមិនបាន ឱ្យសង្ឃសម្តែងទីឱ្យក្តី ធ្វើឱ្យកន្លងហួសប្រមាណក្តី ត្រូវសង្ឃាទិសេស ។ (សិក្ខាបទនេះ នឹងហៅថា “ កុដិការ ” ដូច្នេះវិញក៏បាន ) ។

៧- **មហល្លក** បើកុដិដែលធ្វើនោះមានទាយក ជាម្ចាស់របស់ ធ្វើឱ្យកន្លងហួសប្រមាណនោះបាន, តែត្រូវឱ្យសង្ឃសម្តែងទីឱ្យមុនសិន ទើបធ្វើបាន, បើភិក្ខុមិនបានឱ្យសង្ឃសម្តែងទីឱ្យហើយធ្វើ ត្រូវសង្ឃាទិសេស ។

៨- **អមូលក** ភិក្ខុក្រោធខឹងនឹងភិក្ខុឯទៀត ហើយក្លែងចោទគេដោយអាបត្តិបារាជិក ដោយមិនមានមូលត្រូវសង្ឃាទិសេស ។

៩- **អញ្ញភាគិយ** ភិក្ខុក្រោធខឹងនឹងភិក្ខុឯទៀត ហើយក្លែងរកលេសមានជាតិជាដើម មកចោទគេដោយអាបត្តិបារាជិក ត្រូវសង្ឃាទិសេស ។

១០- **សង្ឃភេទ** ភិក្ខុព្យាយាម ដើម្បីនឹងបំបែកសង្ឃឱ្យបែកគ្នា, សង្ឃបានសូត្រសមនុភាសនកម្មហាមប្រាម ដើម្បីឱ្យលះបង់នូវអំពើដែលប្រព្រឹត្តនោះចេញ, បើមិនលះបង់ ត្រូវសង្ឃាទិសេស ។

១១- **ភេទានុវត្តក** ភិក្ខុប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃនោះ, ភិក្ខុឯទៀតឃាត់ក៏មិនស្តាប់, សង្ឃបានសូត្រសមនុភាសនកម្មហាមប្រាម ដើម្បីឱ្យលះបង់នូវអំពើដែលប្រព្រឹត្តនោះចេញ, បើមិនលះបង់ ត្រូវសង្ឃាទិសេស ។

១២- **ទុព្វចជាតិក** ភិក្ខុប្រកបដោយជាតិអ្នករបឹងរឹងរូសប្រដៅក្រ, ភិក្ខុឯទៀតឃាត់ក៏មិនស្តាប់, សង្ឃបានសូត្រ

សមនុភាសនកម្មហាមប្រាម ដើម្បីឱ្យលះបង់ នូវអំពើដែលប្រព្រឹត្តនោះចេញ, បើមិនលះបង់ ត្រូវសង្ឃាទិសេស ។

១៣- **កុលទូសក** ភិក្ខុទ្រុស្តត្រកូល គឺភិក្ខុដែលប្រចុប-ប្រចែងផ្កាប់ផ្គុនគ្រហស្ថ, សង្ឃបានបណ្ដេញចេញអំពីវត្តហើយ, ត្រឡប់ពោលតិះដៀលសង្ឃវិញ, សង្ឃបានសូត្រសមនុភា-សនកម្មហាមប្រាម ដើម្បីឱ្យលះបង់នូវអំពើដែលប្រព្រឹត្តនោះចេញ, បើមិនលះបង់ ត្រូវសង្ឃាទិសេស ។

តាំងពីសុក្កវិស្សដ្ឋិ រៀងមកដល់អញ្ញភាគិយៈ ៩ សិក្ខាបទនេះ ឈ្មោះបឋមាបត្តិកា ព្រោះត្រូវក្នុងខណៈដែលកន្លងជាដំបូង, ក្រៅអំពីនោះ ៤ សិក្ខាបទទៀត ឈ្មោះយាវតតិយកា ព្រោះត្រូវក្នុងខណៈ ដែលសង្ឃសូត្រសមនុភាសនកម្មចប់អនុ-សាវនា ជាគម្រប់បី ។

## អនិយត ២

១- អលំកម្មនិយ ភិក្ខុអង្គុយក្នុងទីកំបាំងភ្នែកតែពីរនាក់នឹងស្ត្រី, បើមានមនុស្ស, ដែលគួរជឿពាក្យបាន មកពោលពាក្យចោទដោយអាបត្តិ ៣ យ៉ាងគឺ បារាជិក ឬសង្ឃាទិសេស

ឬបាចិត្តិយៈ អាបត្តិណា ១ បើភិក្ខុទទួលប្តេជ្ញាដោយអាបត្តិណា ឱ្យភិក្ខុជាវិន័យធរ កាត់ទោសដោយអាបត្តិនោះ ឬ គេបានចោទបំពោះអាបត្តិណា ឱ្យភិក្ខុជាវិន័យធរ កាត់ទោសបំពោះអាបត្តិនោះ ។

២- នាលំកម្មនិយ ភិក្ខុអង្គុយ ក្នុងទីកំបាំងត្រចៀកតែពីរនាក់នឹងស្ត្រី បើមានមនុស្សដែលគួរជឿពាក្យបាន មកពោលពាក្យចោទដោយអាបត្តិពីរយ៉ាងគឺ សង្ឃាទិសេស ឬ បាចិត្តិយៈ អាបត្តិណា ១, បើភិក្ខុទទួលប្តេជ្ញា ដោយអាបត្តិណា ឱ្យភិក្ខុជាវិន័យធរកាត់ទោសបំពោះអាបត្តិនោះ ឬ គេចោទបំពោះអាបត្តិណា ឱ្យភិក្ខុជាវិន័យធរ កាត់ទោសបំពោះអាបត្តិនោះ ។

និស្សគ្គិយបាចិត្តិយៈ ៣០ បែកចេញជាវគ្គមាន ៣ គឺ ចីវរវគ្គ ១ កោសិយវគ្គ ១ បត្តវគ្គ ១ ក្នុងវគ្គមួយៗ មានសិក្ខាបទដប់ ៗ ។

## ចីវរវគ្គទី ១

១- **បឋមកឋិន** សំពត់ដែលមិនបានវិកប្បមិនបានអធិដ្ឋានហៅថាអតិរេកចីវរ, កាលបើអស់អំណាចអានិសង្សកឋិនហើយ,

ភិក្ខុទុកអតិរេកចីវរនោះ យ៉ាងយូរបំផុតបានត្រឹម ១០ ថ្ងៃ បើទុកឱ្យកន្លងហួសពី ១០ ថ្ងៃទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ គឺអតិរេកចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ។

២- **ទុតិយកឋិន** កាលបើអស់អំណាចអានិសង្សកឋិនហើយ, ភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែ ១ យប់ ក៏ត្រូវនិស្សគ្គិយបាចិត្តយៈ វៀរលែងតែភិក្ខុដែលមានជំងឺហើយបានអវិប្បវាសសម្មតិអំពីសង្ឃ (សិក្ខាបទនេះនឹងហៅថា “ ឧទ្ទោសិត ” ដូច្នេះវិញក៏បាន ) ។

៣- **តតិយកឋិន** បើអកាលចីវរ គឺសំពត់ដែលបានក្រៅចីវរកាល កើតឡើងដល់ភិក្ខុ, ភិក្ខុបានហើយមានបំណង នឹងធ្វើចីវរ តែសំពត់នោះខ្វះធ្វើមិនគ្រាន់, បើមានបំណងថានឹងរកថែមទៀត ឬមានសង្ឃឹមថាមុខជានឹងបានទៀត, គប្បីទុកសំពត់នោះយ៉ាងយូរបំផុតបានត្រឹម ១ ខែ, តែទុកឱ្យកន្លងហួសពី ១ ខែទៅ, បើទុកជាមានសង្ឃឹមថា មុខជានឹងបានទៀត ក៏គង់ត្រូវនិស្សគ្គិយបាចិត្តិយៈ។

៤- **ចីវរធោវន** ភិក្ខុប្រើភិក្ខុនី ដែលមិនមែនជាញាតិឱ្យលាងក្តី ឱ្យជ្រលក់ក្តី ឱ្យគក់ ឬ បោកក្តី នូវចីវរចាស់ត្រូវនិស្សគ្គិយបាចិត្តិយៈ ( សិក្ខាបទនេះនឹងហៅថា “ បុរាណចីវរ ” ដូច្នេះវិញក៏បាន ) ។

៥- **ចីវរប្បដិគ្គហណ** ភិក្ខុទទួលចីវរ អំពីដៃភិក្ខុនី ដែលមិនមែនជាញាតិ ត្រូវនិស្សគ្គិយៈ, វៀរលែងតែប្តូរគ្នា ។

៦- **អញ្ញាតកវិញ្ញត្តិ** ភិក្ខុសូមចីវរអំពីគ្រហស្ថ ដែលមិនមែនជាញាតិ, មិនមែនជាគ្រហស្ថដែលគេបានបវារណា បានមក, ត្រូវនិស្សគ្គិយបាចិត្តិយៈ, វៀរលែងតែមានសម័យ ដែលគួរនឹងសូមចីវរបាន គឺចោរលួចយកចីវរទៅ ឬចីវរអន្តរាយដោយហេតុអ្វីមួយ ។

៧- **តទុត្តរិ** ក្នុងសម័យប៉ុណ្ណោះនោះ ភិក្ខុត្រូវសូមបានតែអន្តរវាសកៈនិងឧត្តរាសង្គៈ គឺស្បង់និងចីពរប៉ុណ្ណោះឯង, បើសូមឱ្យលើសហួសពីនោះទៅ, បានមក, ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៨- **បឋមឧបក្ខដ** បើគ្រហស្ថដែលមិនមែនជាញាតិ, មិនមែនបវារណា គេនិយាយថា គេនឹងប្រគេនចីវរដល់ភិក្ខុឈ្មោះ

នេះ, ភិក្ខុនោះបានដឹងហើយ ក៏ចូលទៅនិយាយឱ្យគេប្រគេន ចីវរយ៉ាងនេះយ៉ាងនោះ ដែលមានតម្លៃ ដែលល្អជាងកំណត់ដើមដែលគេបម្រុងនឹងប្រគេននោះ, បានមក, ត្រូវនិស្សគ្គិយ-បាចិត្តិយៈ ។

៩- **ទុតិយឧបក្ខដ** បើគ្រហស្ថដែលគេបម្រុង នឹងប្រគេនចីវរដល់ភិក្ខុនោះមានច្រើននាក់ តាំងពីពីរនាក់ឡើងទៅ សុទ្ធតែមិនមែនជាញាតិ មិនមែនបវារណា, ភិក្ខុទៅនិយាយឱ្យគេរួបរួមថ្លៃចូលជាមួយគ្នា ឱ្យទិញចីវរដែលមានតម្លៃ ដែលល្អជាងកំណត់ដើម ដែលគេបម្រុងនឹងប្រគេននោះ, បានមក, ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

១០- **រាជ** បើមានអ្នកណា ១ គេនាំយកទ្រព្យមកដើម្បីជាថ្លៃចីវរ ហើយគេសួរភិក្ខុថា “ អ្នកណាជាវេយ្យាវច្ចកររបស់លោក ?” បើភិក្ខុត្រូវការចីវរ ក៏គប្បីសម្តែងញោមវត្ត ឬឧបាសកប្រាប់គេថា “ អ្នកនោះជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ ” លុះគេប្រគល់ថ្លៃចីវរឱ្យដល់វេយ្យាវច្ចករនោះហើយ ប្រាប់ភិក្ខុថា “បើព្រះករុណាត្រូវការចីវរ ចូរនិមន្តទៅឯវេយ្យាវច្ចករឈ្មោះ

នោះចុះ ”, កាលណាបើភិក្ខុនោះត្រូវការចីវរ ក៏គប្បីចូលទៅឯវេយ្យាវច្ចករនោះហើយនិយាយថា “ អាត្មាត្រូវការចីវរ ” ដូច្នេះបានត្រឹមបីដង, បើមិនបានចីវរទេ, ត្រូវទៅឈរឱ្យល្មមតែគេមើលមកឃើញ យ៉ាងច្រើនបំផុតបានត្រឹម ៦ ដងទៀត, បើនៅតែមិនបាន ហើយទៅតឿនទារឱ្យលើសជាងបីដង, ទៅឈរឱ្យលើសជាង ៦ ដង, បានមក, ត្រូវនិស្សគ្គិយបាចិត្តិយ, បើបានទៅតឿនទារនិងបានទៅឈរគ្រប់កំណត់ហើយ នៅតែមិនបានចីវរ, ក៏គប្បីទៅប្រាប់ដល់ម្ចាស់ដើមវិញដោយខ្លួនឯង ឬប្រើបម្រើឱ្យទៅប្រាប់ថា “ របស់នោះមិនបានសម្រេចប្រយោជន៍ដល់ខ្លួនទេ ឱ្យគេទៅទារយករបស់គេវិញចុះ ” ។

## កោសិយវគ្គ ទី ២

១- **កោសិយ** ភិក្ខុធ្វើសន្ថតដោយរោមចៀមលាយចម្រុះដោយសូត្រ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

២- **សុទ្ធកាឡក** ភិក្ខុធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៣- **ទ្វេភាគ** ភិក្ខុនឹងធ្វើសន្ថតថ្មី ឱ្យដាក់រោមចៀមខ្មៅពីរភាគ រោមចៀមសមួយភាគ រោមចៀមក្រហមមួយភាគ ជា ៤ ភាគ, បើមិនធ្វើដូច្នេះ ហើយដាក់រោមចៀមខ្មៅឱ្យច្រើនលើសជាងពីរភាគឡើងទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៤- **ឆព្វស្ស** ភិក្ខុធ្វើសន្ថតថ្មីហើយ, ត្រូវប្រើប្រាស់ឱ្យបានគ្រប់ ៦ ឆ្នាំ, បើមិនទាន់ដល់ ៦ ឆ្នាំ ហើយធ្វើសន្ថតថ្មីទៀត សន្ថតថ្មីនោះជានិស្សគ្គិយៈ ភិក្ខុត្រូវបាចិត្តិយៈ វៀរលែងតែភិក្ខុដែលមានជំងឺ ហើយបានសន្ថតសម្មតិអំពីសង្ឃ ។

៥- **និសីទនសន្ថត** ភិក្ខុនឹងធ្វើសន្ថតសម្រាប់ទ្រាប់អង្គុយ, ត្រូវកាត់យកសន្ថតចាស់មួយចំអាមព្រះសុគតដោយជុំវិញ មកផ្សំលាយបញ្ចូលនឹងសន្ថតថ្មី ដើម្បីនឹងធ្វើសន្ថតថ្មីនោះឱ្យខូចពណ៌, បើមិនធ្វើដូច្នេះ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៦- **ឯឡកលោម** កាលបើភិក្ខុដើរទៅកាន់ផ្លូវឆ្ងាយ, បើមានរោមចៀមកើតឡើងដល់ខ្លួន, ហើយបើមានសេចក្តីត្រូវការ ក៏គប្បីទទួលបុះ, បើមិនមានគេនាំយកទៅឱ្យ, គប្បីនាំទៅដោយ

ខ្លួនឯងបាន យ៉ាងឆ្ងាយបំផុតត្រឹម ៣ យោជន៍, បើនាំឱ្យកន្លងហួសពី ៣ យោជន៍ទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៧- **ឯឡកលោមធោវាបន** ភិក្ខុប្រើភិក្ខុនីដែលមិនមែនជាញាតិ ឱ្យលាងក្តី ឱ្យជ្រលក់ក្តី ឱ្យសិត ឬត្រដោះក្តី នូវរោមចៀម, ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៨- **រូបិយ** ភិក្ខុទទួលដោយខ្លួនឯងក្តី ញុំាងអ្នកឯទៀតឱ្យទទួលក្តី នូវមាសឬប្រាក់ ឬត្រេកអរចំពោះមាសឬប្រាក់ដែលគេទុកដាក់ឱ្យដើម្បីខ្លួនក្តី, ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៩- **រូបិយសំវោហារ** ភិក្ខុ លក់ ទិញ ផ្លាស់ប្តូរដោយរូបិយគឺរបស់ដែលគេប្រើជួសមាសនិងប្រាក់ ត្រូវនិស្សគ្គិយ-បាចិត្តិយៈ ។

១០- **កយវិក្កយ** ភិក្ខុ លក់ ទិញ ផ្លាស់ប្តូរកប្បិយវត្ថុដោយកប្បិយវត្ថុមានប្រការផ្សេងៗ មានចីវរនិងបិណ្ឌបាតជាដើម នឹងគ្រហស្ថ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

## បត្តវគ្គទី ៣

១- **បត្ត** បាត្រដែលមិនបានវិកប្ប មិនបានអធិដ្ឋាន ហៅថាអតិរេកបាត្រ, ភិក្ខុទុកអតិរេកបាត្រនោះ យ៉ាងយូរបំផុតបានត្រឹម ១០ ថ្ងៃ, បើទុកឱ្យកន្លងហួសពី ១០ ថ្ងៃទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

២- **ឩនបញ្ចពន្ធន** បាត្រដែលមានស្នាមប្រេះបែកប្រមាណ ២ ធ្នាប់ ឈ្មោះថាមានបំណាង ១ អន្លើ, ភិក្ខុមានបាត្រមានបំណាងមិនទាន់ដល់ ៥ អន្លើ គឺមានស្នាមប្រេះបែកមិនទាន់ដល់ ១០ ធ្នាប់ ហើយសូមបាត្រថ្មីទៀត អំពីគ្រហស្ថដែលមិនមែនជាញាតិ, មិនមែនបវារណា, បានមក ត្រូវនិស្សគ្គិយបាចិត្តិយៈ។

៣- **ភេសជ្ជ** ភិក្ខុទទួលប្រគេនភេសជ្ជៈប្រាំយ៉ាង គឺទឹកដោះរាវ, ទឹដោះខាប់, ប្រេង, ទឹកឃ្មុំ, ទឹកអំពៅ ភេសជ្ជៈណា ១ ហើយ ត្រូវទុកឆាន់បាន យ៉ាងយូរបំផុតត្រឹម ៧ ថ្ងៃ, បើទុកឱ្យកន្លងហួសពី ៧ ថ្ងៃទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

៤- **វស្សិកសាដិក** កាលជាខាងចុងនៃរដូវក្តៅមួយខែ គិតតាំងពីថ្ងៃ ១ រោច ខែជេស្ឋទៅដល់ថ្ងៃខែដាច់, កន្លះខែនេះ ជាកាលត្រូវភិក្ខុស្វែងរក ព្រមទាំងធ្វើនូវសំពត់សម្រាប់ងូតទឹកភ្លៀង, តាំងពីថ្ងៃ ១ កើត ខែអាសាឍ ទៅដល់ថ្ងៃពេញបូណ៌មី, កន្លះខែនេះ ជាកាលត្រូវភិក្ខុស្វែងរក ព្រមទាំងធ្វើឱ្យសម្រេបនិងស្លៀកផងក៏បាន, បើស្វែងរក, ធ្វើ, ស្លៀក, ឱ្យខុសពីកាលកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៥- **ចីវរាច្ឆិន្ទន** ភិក្ខុបានឱ្យចីវរដល់ភិក្ខុឯទៀត ហើយក្រោធខឹងដណ្តើមយកវិញ ដោយខ្លួនឯងក្តី ប្រើអ្នកឯទៀតឱ្យដណ្តើមយកក្តី បានមក ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៦- **សុត្តវិញ្ញត្តិ** ភិក្ខុសូមអំបោះអំពីគ្រហស្ថដែលមិនមែន ជាញាតិ, មិនមែនបវារណា, យកមកឱ្យជាងតម្បាញត្បាញជាចីវរ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៧- **មហាបេសការ** បើគ្រហស្ថដែលមិនមែនជាញាតិ មិនមែនបវារណា គេឱ្យជាងតម្បាញត្បាញចីវរ ដើម្បីនឹងប្រគេនដល់ភិក្ខុ, បើភិក្ខុទៅនិយាយនឹងជាងតម្បាញឱ្យគេ

ត្បាញឱ្យល្អឡើង ដោយនឹងថែមរង្វាន់ឱ្យទៀត, បានមក ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

៨- **អច្ចេកចីវរ** នៅ១០ ថ្ងៃទៀត នឹងដល់ថ្ងៃបវារណា គឺតាំងពីថ្ងៃ ៥ កើត ខែអស្សុជទៅដល់ថ្ងៃពេញបូណ៌មី, បើមានទាយកគេរវៀសរវៃនឹងប្រគេនសំពត់ចំណាំវស្សាដល់ភិក្ខុ, ភិក្ខុគប្បីទទួលទុកដាក់បានអស់កំណត់ចីវរកាល, បើទុកឱ្យកន្លងហួសពីចីវរកាលទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។ ចីវរកាលនោះដូច្នេះ, បើនៅចាំវស្សារួចហើយ, មិនបានក្រាលកឋិន ចីវរ-កាលមានតែ ១ ខែ គឺតាំងពីថ្ងៃ ១ រោជ ខែអស្សុជ ទៅដល់ថ្ងៃពេញបូណ៌មី ខែកត្តិក បើបានក្រាលកឋិន ចីវរកាលមាន ៥ ខែ គឺតាំងពីថ្ងៃ ១ រោច ខែអស្សុជ ទៅដល់ថ្ងៃពេញបូណ៌មី ខែផល្គុន, ប្រាំខែនេះឈ្មោះថា ចីវរកាល ។

៩- **សាសង្ក** ភិក្ខុនៅចាំវស្សាក្នុងសេនាសនៈក្នុងព្រៃ ដែលជាទីប្រកបដោយរង្កៀសដោយភ័យ, លុះចេញវស្សាហើយ នៅក្នុងរវាងកត្តិកមាសមួយខែ គឺតាំងពីថ្ងៃ ១ រោច ខែអស្សុជទៅដល់ថ្ងៃពេញបូណ៌មី ខែកត្តិក, បើត្រូវការនឹងទុកត្រៃចីវរណា ១

ក្នុងស្រុក, ត្រូវទុកបានតែត្រឹម ១ ខែនោះ, កាលបើមានហេតុនឹងចេញទៅបាកទីនោះ, ត្រូវនៅប្រាសចាកចីវរនោះបានត្រឹម ៦ យប់, បើនៅប្រាសឱ្យហួសពី ៦ យប់ទៅ, ត្រូវនិស្សគ្គិយបាចិត្តិយៈ, វៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ ។

១០- **បរិណាត** ភិក្ខុដឹងថា លាភដែលទាយកគេបម្រុងនឹងប្រគេនដល់សង្ឃហើយ បង្អោនសង្ឃលាភនោះមកដើម្បីខ្លួនវិញ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

សុទ្ធិកបាចិត្តិយៈ ៩២ បែកចេកជាវគ្គមាន ៩ គឺ មុសាវាទវគ្គ ១, ភូតគាមវគ្គ ១, ឱវាទវគ្គ ១, ភោជនវគ្គ ១, អចេលកវគ្គ ១, សុរាបានវគ្គ ១, សប្បាណកវគ្គ ១, សហធម្មិកវគ្គ១, រាជវគ្គ ១, ( រាជវគ្គនេះនឹងហៅថា " រតនវគ្គ " ដូច្នេះវិញក៏បាន ) ។ ក្នុងវគ្គមួយៗ មានសិក្ខាបទ១ដប់ៗ វៀរលែងតែសហធម្មិកវគ្គ ១ មានសិក្ខាបទ ១២ ។

## មុសាវាទវគ្គទី ១

១- **មុសាវាទ** ភិក្ខុនិយាយកុហក ត្រូវបាចិត្តិយៈ ។

២- **ឱមសវាទ** ភិក្ខុជេរប្រទេច ឬ ពោលពាក្យបាក់ដោត ភិក្ខុផងគ្នា ត្រូវបាចិត្តិយៈ ។

៣- **បេសុញ្ញ** ភិក្ខុនិយាយញុះញង់ភិក្ខុផងគ្នា ត្រូវបាចិត្តិយៈ ។

៤- **បទសោធម្ម** ភិក្ខុបង្រៀនធម៌ដល់អនុបសម្បន្ន គឺ សាមណេរ ឬ គ្រហស្ថ ឋាព្រមគ្នា, ត្រូវបាចិត្តិយៈ ។

៥- **បឋមសហសេយ្យ** ភិក្ខុដេកក្នុងទីប្រក់ទីបាំង ជាមួយគ្នានឹងអនុបសម្បន្ន ឱ្យលើសជាង ៣ យប់ឡើងទៅ ត្រូវបាចិត្តិយៈ រាប់អំពីយប់ជាគម្រប់ ៤ ទៅ ។

៦- **ទុតិយសហសេយ្យ** ភិក្ខុដេកក្នុងទីប្រក់ទីបាំងជាមួយនឹងស្ត្រី សូម្បីតែ ១ យប់ ក៏ត្រូវបាចិត្តិយៈ ។

៧- **ធម្មទេសនា** ភិក្ខុសម្តែងធម៌ដល់ស្ត្រី មិនមានបុរសដែលដឹងសេចក្តីនៅជាមួយផង, ឱ្យលើសជាង ៦ ម៉ាត់ឡើងទៅ, ត្រូវបាចិត្តិយៈ ។

៨- **ភូតារោចន** ភិក្ខុប្រាប់ឧត្តរិមនុស្សធម្ម ដែលខ្លួនបានពិតប្រាកដ ដល់អនុបសម្បន្ន ត្រូវបាចិត្តិយៈ ។

៩- **ទុដ្ឋុល្លារោចន** ភិក្ខុប្រាប់ទុដ្ឋុល្លាបត្តិ គឺអាបត្តិសង្ឃាទិសេស ដែលភិក្ខុឯទៀតត្រូវ ដល់អនុបសម្ប័ន្ន ត្រូវបាចិត្តិយៈ វៀរលែងតែភិក្ខុ ដែលសង្ឃសម្មតឱ្យជាអ្នកប្រាប់ ។

១០- **បឋវីខណន** ភិក្ខុជីកដោយខ្លួនឯងក្តី, ប្រើអ្នកឯទៀតឱ្យជីកដោយអកប្បិយវោហារក្តី នូវផែនដី, ត្រូវបាចិត្តិយៈ ។

## ភូតគាមវគ្គទី២

១- **ភូតគាម** ភិក្ខុធ្វើភូតគាម មានដើមឈើនិងវល្លិ៍ជាដើម ដែលកើត ដែលដុះនឹងផែនដី ឬនឹងទីណា ១ ឱ្យដាច់, របេះ, រដក, កម្រើក ឃ្លាតផុតចាកទី ត្រូវបាចិត្តិយៈ ។

២- **អញ្ញវាទក** ភិក្ខុប្រព្រឹត្តអនាចារ, សង្ឃបានហៅខ្លួនមកសាកសួរ, ក្លែងនិយាយបន្លែបន្លប់ក្តី ស្ងៀមមិននិយាយក្តី, បើសង្ឃបានសូត្រប្រកាសសេចក្តីនោះចប់ហើយ, នៅតែធ្វើដូច្នោះ, ត្រូវបាចិត្តិយៈ ។

៣- **ឧជ្ឈាបនក** ភិក្ខុតិះដៀលភិក្ខុឯទៀត ដែលសង្ឃសម្មតឱ្យជាអ្នកធ្វើការសង្ឃ មានក្រាលអាសនៈ និងចែកលាភ

ជាដើម, បើភិក្ខុនោះធ្វើការសង្ឃដោយប្រពៃ, ភិក្ខុអ្នកតិះដៀល ត្រូវបាចិត្តិយៈ ។

៤- **បឋមសេនាសន** ភិក្ខុយកគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ជារបស់សង្ឃ ទៅតាំងទុកនៅទីវាលហើយ, កាលនឹងចៀសចេញទៅបាកទីនោះ, មិនយកមកទុកដាក់ដោយខ្លួនឯងក្តី មិនប្រើអ្នកដទៃឱ្យយកមកទុកដាក់ក្តី ចៀសចេញទៅត្រូវបាចិត្តិយៈ ។

៥- **ទុតិយសេនាសន** ភិក្ខុយកកម្រាលជារបស់សង្ឃមកក្រាលដេកក្នុងកុដិជារបស់សង្ឃ, កាលនឹងចៀសចេញទៅបាកទីនោះ, មិនយកទៅទុកដាក់ដោយខ្លួនឯងក្តី មិនប្រើអ្នកឯទៀតឱ្យយកទៅទុកដាក់ក្តី ចៀសចេញទៅ, ត្រូវបាចិត្តិយៈ ។

៦- **អនុប្បខជ្ជ** ភិក្ខុដឹងថាកុដិជារបស់សង្ឃ មានភិក្ខុចូលទៅនៅមុនហើយ ក្លែងយកកម្រាលទៅក្រាលដេក ហើយបានអង្គុយ ឬ ដេកប្រៀតបៀតក្នុងទីនោះ ដើម្បីនឹងឱ្យភិក្ខុ ដែលនៅមុននោះ មានសេចក្តីបង្អៀតបង្អល់ទញ់ទាល់ចិត្ត ហើយនឹងចៀសចេញទៅ, ត្រូវបាចិត្តិយៈ ។

៧- **និក្កឌ្ឍន** ភិក្ខុក្រោធខឹងនឹងភិក្ខុឯទៀត ហើយទៅចាប់អូសកើបកន្ត្រាក់ដេញភិក្ខុនោះ ឱ្យចេញចាកកុដិជារបស់សង្ឃ, ត្រូវបាចិត្តិយៈ។

៨- **វេហាសកុដិ** ភិក្ខុអង្គុយក្តី ដេកក្តី លើគ្រែ ឬតាំងដែលមានជើង គេគ្រាន់តែផ្គុំទុក នៅមិនទាន់បានបោះកន្លាស់ ឬនៅមិនទាន់បានរួតរឹតឱ្យណែន ដែលគេដាក់តម្កល់ទុកនៅលើធ្នើរសម្រាប់ទើររបស់ក្នុងកុដិ, ត្រូវបាចិត្តិយៈ។

៩- **មហល្លក** ភិក្ខុយកដី ឬកំបោរបូកកុដិ, គប្បីបូកបានយ៉ាងច្រើនបំផុតត្រឹម ៣ ជាន់ បើបូកឱ្យលើសជាង ៣ ជាន់ឡើងទៅ, ត្រូវបាចិត្តិយៈ។

១០- **សប្បាណក** ភិក្ខុដឹងថាទឹកមានសត្វរស់, ហើយយកទៅចាក់ស្រោចស្មៅ ឬដី, ត្រូវបាចិត្តិយៈ។

## ឱវាទវគ្គ ទី ៣

១- **ភិក្ខុនោវាទ** ភិក្ខុដែលសង្ឃមិនបានសម្មត ហើយទៅពោលប្រដៅភិក្ខុនីដោយគរុធម៌ ៨ ប្រការ, ត្រូវបាចិត្តិយៈ។

២- **អដ្ឋង្គត** ទុកជាភិក្ខុ ដែលសង្ឃបានសម្មតហើយនោះក៏ដោយ, កាលបើព្រះអាទិត្យអស្តង្គតទៅហើយ, ប្រដៅភិក្ខុនីត្រូវបាចិត្តិយៈ ។

៣- **ភិក្ខុនូបស្សយ** ភិក្ខុចូលទៅប្រដៅភិក្ខុនី ដល់ទីលំនៅ, ត្រូវបាចិត្តិយៈ វៀរលែងតែភិក្ខុនី ដែលមានជំងឺ ។

៤- **អាមិស** ភិក្ខុពោលតិះដៀលភិក្ខុឯទៀត, ថាប្រដៅភិក្ខុនី ព្រោះអាស្រ័យលាភសក្ការៈ, ត្រូវបាចិត្តិយៈ ។

៥- **ចីវរទាន** ភិក្ខុឱ្យចីវរដល់ភិក្ខុនី ដែលមិនមែនជាញាតិ, ត្រូវបាចិត្តិយៈ វៀរលែងតែប្តូរគ្នា ។

៦- **ចីវរសិព្វន** ភិក្ខុដេរដោយខ្លួនឯងក្តី ប្រើអ្នកឯទៀតឱ្យដេរក្តី នូវចីវររបស់ភិក្ខុនី ដែលមិនមែនជាញាតិ, ត្រូវបា-បិត្តិយៈ ។

៧- **សំវិធាន** ភិក្ខុបបួលភិក្ខុនី ដើរផ្លូវទៅជាមួយគ្នាសូម្បីតែចម្ងាយលង្វែកភូមិ១ ក៏ត្រូវបាចិត្តិយៈ វៀរលែងតែផ្លូវដែលប្រកបដោយរង្កៀស ដោយភ័យផ្សេងៗ ។

៨- **នាវាភិរុហន** ភិក្ខុបបួលភិក្ខុនី ឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្ដី បណ្ដោយទឹកក្ដី ត្រូវបាចិត្តិយៈ, វៀរលែងតែជិះឆ្លងទទឹង ។

៩- **បរិបាចន** ភិក្ខុដឹងហើយ, ឆាន់ខាទនីយភោជនីយាហារ គឺបង្អែមឬបម្អាប ដែលភិក្ខុនីបាត់បែងបង្គាប់គ្រហស្ថឱ្យគេប្រគេន, ត្រូវបាចិត្តិយៈ, វៀរលែងតែគ្រហស្ថគេផ្ដើមឡើងជាមុន ។

១០- **រហោនិសជ្ជ** ភិក្ខុអង្គុយ ឬដេកក្នុងទីកំបាំងភ្នែក តែពីរនាក់នឹងភិក្ខុនី, ត្រូវបាចិត្តិយៈ ។

## ភោជនវគ្គទី ៤

១- **អាវសថបិណ្ឌ** អាហារក្នុងរោងទាន ដែលគេឱ្យទូទៅមិននិយមបុគ្គល, ភិក្ខុមិនមានជំងឺឆាន់បានចំពោះតែថ្ងៃ ១ ហើយត្រូវឈប់បង្អង់ក្នុងបន្លោះ តទៅទើបឆាន់ទៀតបាន, បើឆាន់ជាប់ៗគ្នារៀងរាល់ថ្ងៃ តាំងពីពីរថ្ងៃឡើងទៅ, ត្រូវបាចិត្តិយៈ ។

២- **គណភោជន** បើទាយកនិមន្តបេញឈ្មោះភោជន ៥ យ៉ាង គឺ បាយ ១, នំស្រស់ ១, នំក្រៀម ១, ត្រី ១, សាច់ ១,

ភោជនណាមួយ, បើភិក្ខុទៅទទួលភោជននោះព្រមគ្នាតាំងពី ៤ រូបឡើងទៅ ហើយឆាន់ជាមួយគ្នាក្តី ឆាន់ទីទៃគ្នាក្តី, ត្រូវបាចិត្តិយៈ វៀរលែងតែមានសម័យ ៧ យ៉ាងគឺ ភិក្ខុមានជំងឺ ១, រដូវបីវរកាល ១, វេលាធ្វើចីវរ ១, ដើរផ្លូវឆ្ងាយ ១, ឡើងជិះទូក ១, ភិក្ខុមកជួបជុំគ្នាច្រើនជាងកំណត់ ហើយបិណ្ឌបាតមិនល្មមឆាន់គ្រាន់ ១, ភោជននោះ ជារបស់សមណៈ គឺអ្នកបួសពួកណាមួយគេនិមន្តឆាន់ ១, សម័យទាំង ៧ យ៉ាងនេះ បើមានសម័យណាមួយ ក៏ឆាន់គណភោជនបាន មិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះ បំពោះយកហេតុត្រង់ទទួលភោជន ជាមួយគ្នាជាប្រមាណ) ។

៣- **បរម្បរភោជន** ភិក្ខុទទួលនិមន្តកន្លែង ១ ដោយភោជន ៥ យ៉ាង ឯណាមួយហើយ មិនទៅឆាន់ក្នុងទីនោះ, បែរជាទៅឆាន់ក្នុងទីឯទៀតវិញ, ត្រូវបាចិត្តិយៈ វៀរលែងតែបានលើកបំណែកដែលខ្លួនទទួលនិមន្តនោះឱ្យដល់ភិក្ខុឯទៀត គឺឱ្យគេទៅឆាន់ក្នុងទីនោះជាជំនួសខ្លួន, ឬមានសម័យ ៣ យ៉ាងគឺ ភិក្ខុមានជំងឺ ១, រដូវបីវរកាល ១, វេលាធ្វើចីវរ១, សម័យណាមួយ ។

៤- **កាណមាតា** ភិក្ខុចូលទៅបិណ្ឌបាតក្នុងស្រុក, បើទាយកគេយកនំមកប្រគេនច្រើន, គប្បីទទួលយ៉ាងច្រើនបំផុតបានត្រឹម ៣ បាត្រ, បើទទួលឱ្យច្រើនលើសហួសកំណត់នោះ, ត្រូវបាចិត្តិយៈ នំដែលភិក្ខុទទួលពីរបាត្រ ឬបីបាត្រហើយនោះ ត្រូវឱ្យរំលែកចែកភិក្ខុឯទៀតឆាន់ផង ទើបគួរ ។

៥- **បឋមប្បវារណា** ភិក្ខុកំពុងឆាន់មិនទាន់លែង, បើមានទាយកគេយកភោជន ៥ យ៉ាង ណាមួយ ចូលមកប្រគេនក្នុងហត្ថបាស គឺពីរហត្ថមួយចំអាម, មិនទទួលភោជននោះឈ្មោះថាឃាមភោជន, ភិក្ខុឃាមភោជនយ៉ាងនេះហើយក្រោកចាកទីនោះ ទៅឆាន់ខាទនីយភោជនីយាហារ ដែលមិនមែនជាដែលភិក្ខុឈឺ ឬដែលមិនបានធ្វើវិនយកម្ម, ត្រូវបាចិត្តិយៈ ។

៦- **ទុតិយប្បវារណា** ភិក្ខុដឹងថាភិក្ខុឯទៀតឃាមភោជនដូច្នោះហើយ គិតនឹងលើកទោសភិក្ខុនោះ, ហើយក្លែងយកខាទនីយភោជនីយាហារ ដែលមិនមែនជាភិក្ខុដែលឈឺ ឬ

ដែលមិនបានធ្វើវិនយកម្ម ទៅអង្វរ ឬ បង្ខំឱ្យភិក្ខុនោះឆាន់, បើភិក្ខុនោះឆាន់ហើយ, ភិក្ខុអ្នកអង្វរ ឬ បង្ខំឱ្យឆាន់នោះ ត្រូវបាចិត្តិយៈ ។

**៧- វិកាលភោជន** ភិក្ខុឆាន់ខាទនីយភោជនីយាហារ ក្នុងវេលាវិកាល គឺតាំងពីព្រះអាទិត្យជ្រេពីត្រង់ហើយ ទៅទល់អរុណរះឡើង, ត្រូវបាចិត្តិយៈ ។

**៨- សន្និធិការក** ភិក្ខុឆាន់ខាទនីយភោជនីយាហារ ដែលទទួលប្រគេនហើយ ទុកឱ្យកន្លងរាត្រី ត្រូវបាចិត្តិយៈ ។

**៩- បណីតភោជន** ភិក្ខុមិនមានជំងឺ សូមបណីតភោជន គឺបាយដែលលាយដោយវត្ថុឧត្តម ៩ យ៉ាងគឺ ទឹកដោះរាវ ១, ទឹកដោះខាប់ ១, ប្រេង ១, ទឹកឃ្មុំ ១, ទឹកអំពៅ ១, ត្រី ១, សាច់ ១, ទឹកដោះស្រស់ ១, ទឹកដោះជូរ ១, វត្ថុឧត្តមណាមួយ, អំពីគ្រហស្ថដែលមិនមែនជាញាតិ មិនមែនបវារណា យកមកឆាន់ ត្រូវបាចិត្តិយៈ ។

**១០- ទន្តបោណ** ភិក្ខុឆាន់អាហារ ដែលមិនបានទទួលប្រគេន ត្រូវបាចិត្តិយៈ, វៀរលែងតែទឹកសុទ្ធនិងឈើស្ទន់ ។

## អចេលកវគ្គ ទី ៥

១- **អចេលក** ភិក្ខុឱ្យខាទនីយភោជនីយាហារ ដល់អ្នកបួសក្រៅព្រះពុទ្ធសាសនា ដោយដៃខ្លួនឯង, ត្រូវបាចិត្តិយៈ ។

២- **ឧយ្យោជន** ភិក្ខុបបួលភិក្ខុឯទៀត ទៅបិណ្ឌបាត ជាមួយគ្នា, គិតនឹងប្រព្រឹត្តអនាចារ, ហើយបណ្ដេញភិក្ខុនោះឱ្យត្រឡប់មកវិញ, ត្រូវបាចិត្តិយៈ ។

៣- **សភោជន** ភិក្ខុចូលទៅអង្គុយក្នុងផ្ទះ ដែលមិនមានអ្នកឯទៀតនៅ ៗ នោះផង, មានតែប្ដីប្រពន្ធគេនៅតែពីរនាក់ប៉ុណ្ណោះ ត្រូវបាចិត្តិយៈ ។

៤- **រហោបដិច្ឆន្ន** ភិក្ខុអង្គុយ ឬដេកក្នុងទីកំបាំងភ្នែក ជាមួយនឹងស្ត្រី មិនមានមនុស្សប្រុសនៅជាមួយផង, ត្រូវបាចិត្តិយៈ (សិក្ខាបទនេះនឹងហៅថា "បឋមរហោនិសជ្ជ" ដូច្នេះវិញក៏បាន) ។

៥- **រហោនិសជ្ជ** ភិក្ខុអង្គុយ ឬ ដេកក្នុងទីកំបាំងត្រចៀកតែពីរនាក់នឹងស្ត្រី ត្រូវបាចិត្តិយៈ (សិក្ខាបទនេះនឹងហៅថា "ទុតិយរហោនិសជ្ជ" ដូច្នេះវិញក៏បាន) ។

៦- **បារិត្ត** ភិក្ខុទទួលនិមន្តគេដោយភោជន ៥ យ៉ាង ឯណាមួយហើយ, នឹងទៅក្នុងទីដទៃ អំពីទីដែលគេនិមន្តនោះ ក្នុងវេលាមុនឆាន់ក្តី ឆាន់រួចហើយក្តី តាំងពីពេលព្រឹកទៅទល់នឹងថ្ងៃត្រង់, ត្រូវលាភិក្ខុ ដែលមាននៅក្នុងទីនោះសិន ទើបទៅបាន, បើមិនបានលាហើយទៅ, ត្រូវបាចិត្តិយៈ, វៀរលែងតែមានសម័យ ២ យ៉ាងគឺ រដូវចីវរកាល ១, វេលាធ្វើចីវរ ១, សម័យណាមួយ ។

៧- **មហានាម** បើទាយកគេបវារណា ដោយបច្ច័យ ៤ កំណត់កាលត្រឹម ៤ ខែ ឬមានកំណត់បច្ច័យ, ភិក្ខុមិនមានជំងឺគប្បីសូមគេបានតែត្រឹមកំណត់កាល ឬ កំណត់បច្ច័យនោះប៉ុណ្ណោះ បើសូមឱ្យលើសជាងកំណត់នោះទៅ, ត្រូវបាចិត្តិយៈ វៀរលែងតែគេបានបវារណាទៀត ឬគេបវារណាជានិច្ច ។

៨- **ឧយ្យុត្ត** ភិក្ខុទៅមើលកងទ័ព ដែលគេលើកទៅដើម្បីនឹងច្បាំងគ្នា, ត្រូវបាចិត្តិយៈ វៀរលែងតែមានហេតុ ដែលគួរនឹងទៅបាន គឺមានញាតិឈឺក្នុងទីនោះ ។

៩- **សេនាវាស** បើហេតុដែលគួរនឹងទៅបាននោះមាន, ភិក្ខុគប្បីទៅនៅក្នុងកងទ័ពនោះ យ៉ាងយូរបំផុតបានត្រឹមបីថ្ងៃ បើនៅឱ្យលើសជាងកំណត់នោះទៅ, ត្រូវបាចិត្តិយៈ ។

១០- **ឧយ្យោធិក** ក្នុងវេលាដែលនៅក្នុងកងទ័ព តាមកំណត់កាលនោះ, បើភិក្ខុដើរទៅកាន់ទីដែលគេច្បាំងគ្នាក្តី ទីដែលរាប់ពលក្តី ទីដែលគេចាត់ចែងរៀបក្បួនទ័ពក្តី ទៅមើលពួកសេនាទាហាន ដែលគេចាត់ចែងរៀបជាក្បួនទ័ពរួបហើយក្តី, ត្រូវបាចិត្តិយៈ ។

## សុរាបានវគ្គ ទី៦

១- **សុរាបាន** ភិក្ខុផឹកទឹកស្រវឹង ត្រូវបាចិត្តិយៈ ។

២- **អង្គុលិប្បតោទក** ភិក្ខុយកម្រាមដៃចាក់ភិក្ខុឯទៀតលេង ត្រូវបាចិត្តិយៈ ។

៣- **ហាសធម្ម** ភិក្ខុលេងទឹក ត្រូវបាចិត្តិយៈ ។

៤- **អនាទរិយ** ភិក្ខុសម្តែងសេចក្តីមិនអើពើនឹងវិន័យ ឬនឹងបុគ្គលជាអ្នកសម្តែងវិន័យ ត្រូវបាចិត្តិយៈ ។

៥- **ភឹសាបន** ភិក្ខុពញ្ញាក់ ឬ លងបន្លាចភិក្ខុផងគ្នា ត្រូវបាចិត្តិយៈ ។

៦- **ជោតិសមាទហន** ភិក្ខុមិនមានជំងឺ, បង្កាត់ភ្លើងឱ្យមានជាអណ្ដាតឡើងដោយខ្លួនឯងក្ដី ប្រើអ្នកដទៃឱ្យបង្កាត់ក្ដី ដើម្បីនឹងអាំង, ត្រូវបាចិត្តិយៈ, បើបង្កាត់ដើម្បីហេតុឯទៀតមាន ដុតបាត្រជាដើមនោះ ទើបមិនត្រូវអាបត្តិ ។

៧- **នហាន** ភិក្ខុនៅក្នុងមជ្ឈិមប្រទេស, ១៥ ថ្ងៃ ទើបងូតទឹកម្ដងបាន, បើមិនទាន់ដល់ ១៥ ថ្ងៃហើយងូត, ត្រូវបាចិត្តិយៈ, វៀរលែងតែមានសម័យ ដែលគួរនឹងងូតបាន (សិក្ខាបទនេះជាបទេសប្បញ្ញត្តិ បំពោះតែក្នុងមជ្ឈិមប្រទេស, ឯក្នុងបច្ចន្តប្រទេស ដូចកម្ពុជាប្រទេសយើងនេះ គួរងូតទឹកបានជានិច្ច មិនត្រូវអាបត្តិឡើយ ) ។

៨- **ទុព្វណ្ណករណ** ភិក្ខុបានចីវរថ្មីមក, បើត្រូវការប្រើប្រាស់, គប្បីធ្វើពិន្ទុកប្បដោយវត្ថុមានពណ៌ ៣ យ៉ាងគឺ វត្ថុមានពណ៌ខៀវយ៉ាងពណ៌ធ្នះ ១, ពណ៌ប្រផេះយ៉ាងពណ៌ភក់ ១, ពណ៌ខ្មៅដាំ ១, វត្ថុមានពណ៌ណា ១ ហើយ ទើបស្លៀកដណ្ដប់បាន, បើមិនទាន់ធ្វើពិន្ទុកប្បសិន ហើយស្លៀកដណ្ដប់, ត្រូវបាចិត្តិយៈ ។

៩- **វិកប្បន** ភិក្ខុវិកប្ប គឺផ្ញើចីវរទុកនឹងសហធម្មិកទាំង ៥ គឺ ភិក្ខុ, ភិក្ខុនី, សិក្ខមានា, សាមណេរ, សាមណេរី, សហធម្មិកណាមួយហើយ, មិនឱ្យអ្នកទទួលវិកប្ប ដកវិកប្បឱ្យសិន, ហើយយកចីវរនោះមកស្លៀកដណ្ដប់, ត្រូវបាចិត្តិយ: (សិក្ខាបទនេះនឹងហៅថា “ បច្ចុទ្ធារ ” ដូច្នេះវិញក៏បាន) ។

១០- **អបនិធាន** ភិក្ខុលាក់បរិក្ខារ ៥ យ៉ាងគឺ បាត្រ ១, ចីវរ ១, និសីទន: ១, បំពង់ម្ជុល ១, វត្ថពន្ធបង្កេះ ១, បរិក្ខារណាមួយ ជារបស់ភិក្ខុឯទៀត, ដោយមានបំណងថា នឹងសើចលេង, ត្រូវបាចិត្តិយ:

## សប្បាណកវគ្គទី ៧

១- **សញ្ចិច្ចបាណ** ភិក្ខុក្លែងសម្លាប់សត្វតិរច្ឆាន ត្រូវបាចិត្តិយ: ។

២- **សប្បាណក** ភិក្ខុដឹងថាទឹកមានសត្វរស់, ហើយបរិភោគនូវទឹកនោះ គឺផឹក ឬ ងូត ឬ លាងដៃជើង ឬក៏លាងភាជន៍ជាដើម ត្រូវបាចិត្តិយ: ។

៣- **ឧក្កោដន** ភិក្ខុដឹងថា អធិករណ៍ណាមួយ ដែលសង្ឃបានរម្ងាប់ដោយសមថៈ ៧ យ៉ាង ណាមួយ ដោយត្រឹមត្រូវតាមធម៌ជាស្រេចហើយ មកសើរើសេចក្ដីជាថ្មីទៀត, ត្រូវបាចិត្តិយៈ ។

៤- **ទុដ្ឋុល្លប្បដិច្ឆាទន** ភិក្ខុដឹងថា ភិក្ខុឯទៀត ត្រូវទុដ្ឋុល្លាបត្តិ គឺអាបត្តិសង្ឃាទិសេសហើយ, ជួយបិទបាំងអាបត្តិនោះ ត្រូវបាចិត្តិយៈ ។

៥- **ឩនវីសតិវស្ស** ភិក្ខុដឹងថាកុលបុត្រមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ, ហើយធ្វើជាឧបជ្ឈាយ៍ ឱ្យឧបសម្បទា ដល់កុលបុត្រនោះ, ត្រូវបាចិត្តិយៈ, ឯកុលបុត្រនោះ ក៏នៅជាសាមណេរ មិនបានឡើងឧបសម្បទា ជាភិក្ខុភាវៈឡើយ (សិក្ខាបទនេះនឹងហៅថា " ឩនវីសតិវស្ស " ដូច្នេះវិញក៏បាន ) ។

៦- **ថេយ្យសថ** ភិក្ខុដឹងថា ឈ្មួញដែលគិតនឹងបាំងសួយព្រះរាជធានី នឹងរត់រំលងគយ, ហើយបបួលដើរផ្លូវទៅជាមួយគ្នា សូម្បីតែកន្លងលង្វែកភូមិ ១ ក៏ត្រូវបាចិត្តិយៈ ។

**៧- សំវិធាន** ភិក្ខុបបួលស្ត្រីដើរផ្លូវជាមួយគ្នា សូម្បីតែកន្លងលង្វែកភូមិ ១ ក៏ត្រូវបាចិត្តិយៈ (សិក្ខាបទនេះ នឹងហៅ-ថា “ មាតុគ្គាមសំវិធាន ” ដូច្នេះវិញក៏បាន) ។

**៨- អរិដ្ឋ** ភិក្ខុប្រកាន់ទិដ្ឋិបាប គឺមានសេចក្ដីយើញខុសបាកធម៌វិន័យ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងហើយ, ភិក្ខុឯទៀតពោលហាមប្រាម ក៏មិនស្ដាប់, កាលបើសង្ឃបានសូត្រសមនុភាសនកម្មចប់អនុសាវនជាគម្រប់ ៣ ហើយ, នៅតែមិនលះបង់, ត្រូវបាចិត្តិយៈ ។

**៩- ឧក្ខិត្តសម្ភោគ** ភិក្ខុដឹងថា ភិក្ខុនោះមិនទាន់លះបង់ទិដ្ឋិបាបដូច្នោះហើយ ទៅសេពសមគប់នឹងភិក្ខុនោះ គឺឆាន់ជាមួយក្ដី ធ្វើសង្ឃកម្មជាមួយក្ដី ដេកនៅក្នុងទីប្រក់ទីបាំងជាមួយក្ដី, ត្រូវបាចិត្តិយៈ ។

**១០- កណ្ឌក** ភិក្ខុដឹងថា សាមណេរ ដែលភិក្ខុឯទៀត ឱ្យវិនាសហើយ ព្រោះទោសដែលឃើញខុសបាកធម៌វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងហើយ, ប្រលោមសាមណេរនោះមក

ឱ្យបម្រើខ្លួនក្តី រួមបរិភោគក្តី ឱ្យដេកនៅក្នុងទីប្រក់ទីបាំងជាមួយក្តី, ត្រូវបាចិត្តិយៈ ។

## សហធម្មិកវគ្គទី ៨

១- សហធម្មិក ភិក្ខុប្រព្រឹត្តអនាចារ, កាលបើភិក្ខុឯទៀតនិយាយដាស់តឿន, ក៏និយាយតប-តប្រកែកប្រណាំងថា "ខ្ញុំករុណា មិនទាន់សិក្សាសិក្ខាបទនេះទេ បាំខ្ញុំករុណាសាកសួរលោកអ្នកឈ្លាស អ្នកចេះដឹង អ្នកទ្រទ្រង់វិន័យសិន" ពោលពាក្យដូច្នេះ, ត្រូវបាចិត្តិយៈ ធម្មតាភិក្ខុអ្នកសិក្សា, បើនៅមិនទាន់ចេះដឹងច្បាស់លាស់ត្រង់កិច្ចណា, ត្រូវតែខំសង្វាតសិក្សាឱ្យចេះដឹងត្រង់កិច្ចនោះ, ត្រូវសាកសួរលោកអ្នកចេះ ឱ្យលោកប្រាប់ពន្យល់ឱ្យបានចេះដឹងច្បាស់ឡើង ។

២- **វិលេខន** កាលបើភិក្ខុឯទៀតកំពុងទន្ទេញវិន័យ, ភិក្ខុក្លែងនិយាយតិះដៀលសិក្ខាបទ បន្ទុញបន្ថប់ឱ្យគេកើតរាយមាយរសាយបាកព្យាយាមនោះ, ត្រូវបាចិត្តិយៈ ។

៣- **មោហន** ភិក្ខុត្រូវអាបត្តិហើយ ក្លែងនិយាយថា ខ្ញុំករុណា ទើបតែនឹងដឹងអម្បាញ់មិញនេះឯង ថាសេចក្តីនេះមាន

ក្នុងបាតិមោក្ខ" បើភិក្ខុឯទៀតដឹងថា ភិក្ខុនោះធ្លាប់ដឹងមកពីមុនហើយ ដែលពោលដូច្នោះនោះ គឺពោលដោយក្លែងពើធ្វើជាមិនដឹងទៅទេ, សង្ឃគប្បីសូត្រប្រកាស មោហារោបនកម្មដល់ភិក្ខុនោះ, កាលបើសង្ឃបានសូត្រប្រកាស មោហោរោបនកម្មនោះចប់ហើយ,នៅតែក្លែងពើធ្វើជាមិនដឹងដូច្នេះទៀត, ត្រូវបាចិត្តិយៈ

៤- **បហារទាន** ភិក្ខុក្រោធខឹងនឹងភិក្ខុឯទៀត ហើយប្រហារភិក្ខុនោះ ដោយបហារទាន មានទះ, តប់ ដាល់, ទាត់, ធាក់ជាដើម ត្រូវបាចិត្តិយៈ ។

៥- **តលសត្តិក** ភិក្ខុក្រោធខឹងនឹងភិក្ខុឯទៀត ហើយងាដៃឡើងជន្ល ដូចជានឹងប្រហារភិក្ខុនោះ ត្រូវបាចិត្តិយៈ ។

៦- **អមូលក** ភិក្ខុចោទភិក្ខុឯទៀត ដោយអាបត្តិសង្ឃាទិសេស ដោយមិនមានមូល គឺថាមិនបានឃើញ, មិនបានឮ, មិនបានរង្កៀសឡើយ ត្រូវបាចិត្តិយៈ ។

៧- **សញ្ចិច្ច** ភិក្ខុក្លែងធ្វើឱ្យសេចក្តីរង្កៀស សង្ស័យព្រួយចិត្តកើតឡើង ដល់ភិក្ខុឯទៀត សូម្បីតែ ១ ស្របក់ក៏ត្រូវបាចិត្តិយៈ ។

៨- **ឧបស្សុតិ** កាលបើភិក្ខុទាំងឡាយ កំពុងវិវាទទាស់ទែងគ្នា, “ ភិក្ខុទៅលបបចាំស្តាប់ដោយគិតថា ភិក្ខុទាំងឡាយនេះនិយាយនូវពាក្យណា អញនឹងស្តាប់នូវពាក្យនោះ”, ហើយមានបំណងនឹងបោទផង, ត្រូវបាចិត្តិយៈ ។

៩- **កម្មប្បដិពាហន** ភិក្ខុបានឱ្យឆន្ទៈ គឺសេចក្តីយល់ព្រមឱ្យសង្ឃធ្វើសង្ឃកម្ម ដែលប្រកបដោយធម៌ហើយ, ដល់មកខាងក្រោយ ត្រឡប់ពោលតិះដៀលសង្ឃ ដែលធ្វើសង្ឃកម្មនោះវិញ, ត្រូវបាចិត្តិយៈ ។

១០- **បក្កមន** កាលបើសង្ឃកំពុងប្រជុំគ្នារម្ងាប់អធិករណ៍ ឬធ្វើសង្ឃកម្មណាមួយ, សង្ឃធ្វើការនោះនៅមិនទាន់ហើយស្រេច, ភិក្ខុណានៅក្នុងទីប្រជុំនោះ, មិនបានឱ្យឆន្ទៈហើយក្រោកចៀសចេញទៅ, ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយៈ (សិក្ខាបទនេះនឹងហៅថា “ឆន្ទំអទត្វាគមន” ដូច្នេះវិញក៏បាន) ។

១១- **ទិយ្យធម្ម** ភិក្ខុព្រមព្រៀងជាមួយនឹងសង្ឃ បានឱ្យចីវរជាបំណាច់ដល់ភិក្ខុណាមួយហើយ, ដល់មកខាងក្រោយត្រឡប់ពោលតិះដៀលថា “ភិក្ខុទាំងឡាយនេះបង្អោនលាភសង្ឃ

ឱ្យដល់ភិក្ខុ តាមដោយយល់មុខ ”, ដូច្នេះ ត្រូវបាចិត្តិយៈ (សិក្ខាបទនេះនឹងហៅថា “ ទព្វ ” ដូច្នេះវិញក៏បាន) ។

**១២- បរិណាមន** ភិក្ខុដឹងថា លាភដែលទាយកគេបម្រុងនឹងប្រគេនដល់សង្ឃ, ហើយបង្អោនសង្ឃលាភនោះមកដើម្បីបុគ្គលវិញ, ត្រូវបាចិត្តិយៈ ។

## រាជវគ្គ ទី ៩

**១- អន្តេបុរ** ព្រះមហាក្សត្រីយ៍ ដែលបានមុទ្ធាភិសេកជាម្ចាស់ផែនដីហើយ, ស្តេចកំពុងគង់នៅក្នុងក្រឡាបន្ទំ ជាមួយនឹងព្រះមហេសី, ភិក្ខុមិនទាន់បានទទួលរាជានុញ្ញាតថា ឱ្យចូលទៅ, ហើយចូលទៅក្នុងស្លែងក្រឡាបន្ទំនោះ, ត្រូវបាចិត្តិយៈ ។

**២- រតន** ភិក្ខុឃើញគ្រឿងប្រើប្រាស់របស់គ្រហស្ថ ដែលធ្លាក់ ឬដែលគេភ្លេចក្នុងទីណាមួយ, កាន់យកជារបស់រើសបានដោយខ្លួនឯងក្តី ប្រើអ្នកឯទៀតឱ្យកាន់យកជារបស់រើសបានក្តី, ត្រូវបាចិត្តិយៈ, វៀរលែងតែរបស់នោះធ្លាក់ ឬគេភ្លេចនៅក្នុងវត្ត ឬក្នុងទីជាទីនៅអាស្រ័យ, ត្រូវរើសទុកឱ្យដល់ម្ចាស់របស់គេផង បើមិនរើសទុក ត្រូវទុក្កដ ។

៣- **វិកាលេគាមប្បវេសន** ភិក្ខុមិនបានប្រាប់ មិនបានលាភិក្ខុផងគ្នា ដែលមាននៅក្នុងវត្តសិន, ហើយចូលទៅក្នុងស្រុក ក្នុងវេលាវិកាល, ត្រូវបាចិត្តិយៈ វៀរលែងតែមានកិច្ចការប្រញាប់មានពស់ចឹកភិក្ខុផងគ្នាជាដើម ។

៤- **សូចិឃរេ** ភិក្ខុធ្វើបំពង់ម្ជុលនឹងឆ្អឹងក្តី, នឹងភ្លុកក្តី, នឹងស្នែងក្តី, ត្រូវបាចិត្តិយៈ, ត្រូវឱ្យទម្លាយបំពង់ម្ជុលនោះចេញជាវិនយកម្មសិន ទើបសម្តែងអាបត្តិនោះដាច់ ។

៥- **មញ្ចេ** ភិក្ខុនឹងធ្វើគ្រែឬតាំង គប្បីធ្វើឱ្យមានជើងយ៉ាងខ្ពស់បំផុតត្រឹម ៨ ធ្នាប់ព្រះសុគត គិតពីត្រឹមមេគ្រែខាងក្រោមចុះមក, បើធ្វើឱ្យហួសពីប្រមាណនេះ, ត្រូវបាចិត្តិយៈ, ត្រូវកាត់ឱ្យត្រូវនឹងប្រមាណ ជាវិនយកម្មសិន ទើបសម្តែងអាបត្តិនោះដាច់ (សិក្ខាបទនេះ នឹងហៅថា “ឆេទនក” ដូច្នេះវិញក៏បាន) ។

៦- **តុលោនទ្ធេ** ភិក្ខុធ្វើគ្រែ ឬ តាំង ញាត់ដោយគរ ឬសំឡី, ត្រូវបាចិត្តិយៈ, ត្រូវទម្លាយកកាយចេញ ជាវិនយកម្មសិន ទើបសម្តែងអាបត្តិនោះដាច់ ។

**៧- និសីទន** ភិក្ខុនឹងធ្វើសំពត់សម្រាប់ក្រាលអង្គុយ គប្បីធ្វើឱ្យត្រូវនឹងប្រមាណ ប្រមាណនោះ គឺបណ្ដោយ ២ បំអាម ទទឹង ១ បំអាមកន្លះជាយ ១ បំអាម ដោយបំអាមព្រះសុគត, បើធ្វើឱ្យហួសពីប្រមាណនេះ, ត្រូវបាចិត្តិយៈ, ត្រូវកាត់ឱ្យត្រូវនឹងប្រមាណ ជាវិនយកម្មសិន ទើបសម្ដែងអាបត្តិនោះជាប់ ។

**៨- កណ្ឌុប្បដិច្ឆាទិ** ភិក្ខុនឹងធ្វើសំពត់សម្រាប់គ្របបូស, គ្របដំបៅ, គប្បីធ្វើឱ្យត្រូវនឹងប្រមាណ ប្រមាណនោះ គឺបណ្ដោយ ៤ បំអាម ទទឹង ២ បំអាម ដោយបំអាមព្រះសុគត, បើធ្វើឱ្យហួសពីប្រមាណនេះ, ត្រូវបាចិត្តិយៈ ត្រូវកាត់ឱ្យត្រូវនឹងប្រមាណ ជាវិនយកម្មសិន ទើបសម្ដែងអាបត្តិនោះជាប់ ។

**៩- វស្សិកសាដិកា** ភិក្ខុនឹងធ្វើសំពត់សម្រាប់ងូតទឹកភ្លៀង, គប្បីធ្វើឱ្យត្រូវនឹងប្រមាណ ប្រមាណនោះគឺ បណ្ដោយ ៦ បំអាម ទទឹង ២ បំអាមកន្លះ ដោយបំអាមព្រះសុគត, បើធ្វើឱ្យហួសពីប្រមាណនេះ, ត្រូវបាចិត្តិយៈ, ត្រូវកាត់ឱ្យត្រូវនឹងប្រមាណ ជាវិនយកម្មសិន ទើបសម្ដែងអាបត្តិនោះជាប់ ។

១០- **ឆន្ន** ភិក្ខុធ្វើចីវរឱ្យវែង ឱ្យធំប៉ុនចីវរព្រះសុគត, ត្រូវបាចិត្តិយៈ ឯប្រមាណនៃចីវរព្រះសុគតនោះគឺ បណ្ដោយ ៩ បំអាម ទទឹង ៦ បំអាម ដោយបំអាមព្រះសុគត, ត្រូវកាត់ឱ្យត្រូវនឹងប្រមាណគឺ ឱ្យខ្លី ឱ្យតូច ជាងចីវរព្រះសុគត ជាវិនយកម្មសិន ទើបសម្ដែងអាបត្តិនោះជាប់ (សិក្ខាបទនេះនឹងហៅថា “ ឆន្នត្ថេរ ” ដូច្នេះវិញក៏បាន) ។

## បាដិទេសនីយៈ ៤

១- **ហត្ថតោ បដិគ្គហណោ** ភិក្ខុទទួលខាទនីយភោជនីយាហារ អំពីដៃភិក្ខុនី ដែលមិនមែនជាញាតិ ដោយដៃខ្លួនឯងមកបរិភោគ ត្រូវបាដិទេសនីយៈ ។

២- **កុលេសុ និមន្តិត** ភិក្ខុកំពុងឆាន់ក្នុងទីដែលគេនិមន្ត, បើមានភិក្ខុនីមកនិយាយបង្គាប់ទាយកឱ្យយករបស់នេះ របស់នោះប្រគេនភិក្ខុ តាមដោយសេចក្ដីស្រឡាញ់រាប់អាន, ភិក្ខុគប្បីបណ្ដេញភិក្ខុនីឱ្យថយចេញទៅ, បើមិនបណ្ដេញ, ត្រូវបាដិទេសនីយៈ ។

៣- **សេក្ខសម្មត** ត្រកូលណាដែលសង្ឃបានសម្មតថាជាសេក្ខត្រកូលហើយ, បើត្រកូលនោះគេឥតបាននិមន្តឡើយ, ភិក្ខុមិនមានជំងឺ ទៅទទួលខាទនីយភោជនីយាហារ អំពីត្រកូលនោះមកបរិភោគ, ត្រូវបាដិទេសនីយៈ ។

៤- **អារញ្ញិកសេនាសន** ភិក្ខុនៅក្នុងសេនាសនៈក្នុងព្រៃដែលជាទីប្រកបដោយរង្កៀស ដោយភ័យ, បើមិនមានជំងឺ, ទទួលខាទនីយភោជនីយាហារ អំពីទាយក ដែលគេបានឱ្យដំណឹងមកជាមុនថា គេនឹងមកប្រគេនបង្ហាន់ក្នុងទីនោះ, ហើយភិក្ខុមិនបានប្រាប់ឱ្យគេដឹងអំពីសេចក្តីរង្កៀស អំពីភ័យ ដែលមាននៅក្នុងទីនោះ, ដោយដៃខ្លួនឯងមកបរិភោគ, ត្រូវបាដិទេសនីយៈ ។

## សេខិយវត្ត ៧៥

វត្តដែលភិក្ខុសាមណេរគប្បីសិក្សា ហៅថា សេខិយវត្តៗនោះបាត់ជា ៤ ពួក ពួកទី ១ ឈ្មោះ សារូប, ពួកទី ២ ឈ្មោះ ភោជនប្បដិសំយុត្ត, ពួកទី ៣ ឈ្មោះ ធម្មទេសនាបដិសំយុត្ត, ពួក ទី ៤ ឈ្មោះ បកិណ្ណកៈ ។

# សារូបទី ១ មាន ២៦ គឺ

| | | | |
|---|---|---|---|
| ១<br>២ | ភិក្ខុគប្បីសក្សាថា អញនឹង | ស្លៀក<br>ដណ្តប់ | ឱ្យជាបរិមណ្ឌល ។ |
| ៣<br>៤ | ភិក្ខុគប្បីសិក្សាថា អញនឹងបិទបាំងកាយឱ្យល្អ | ដើរទៅ<br>អង្គុយនៅ | ក្នុងបន្លោះផ្ទះ ។ |
| ៥<br>៦ | ។ ល។ អញនឹងសង្រួមប្រយ័ត្នដៃជើងដោយល្អ | ដើរទៅ<br>អង្គុយនៅ | ក្នុងបន្លោះផ្ទះ ។ |
| ៧<br>៨ | ។ ល ។ អញនឹងមានភ្នែកសម្លឹងចុះក្រោម ។ ល។ | ដើរទៅ<br>អង្គុយនៅ | ក្នុងបន្លោះផ្ទះ ។ |
| ៩<br>១០ | ។ ល ។ អញនឹងមិនសើយចីវរលាត់កង្ហើញ | ដើរទៅ<br>អង្គុយនៅ | ក្នុងបន្លោះផ្ទះ ។ |
| ១១<br>១២ | ។ ល ។ អញនឹងមិនសើចខ្លាំង | ដើរទៅ<br>អង្គុយនៅ | ក្នុងបន្លោះផ្ទះ ។ |
| ១៣<br>១៤ | ។ ល ។ អញនឹងនិយាយសំឡេងតិចៗ | ដើរទៅ<br>អង្គុយនៅ | ក្នុងបន្លោះផ្ទះ ។ |

១៥ }
១៦ } ។ ល ។ អញនឹងមិនគ្រលែងខ្លួន ដើរទៅ / អង្គុយនៅ } ក្នុងបន្លោះផ្ទះ ។

១៧ }
១៨ } ។ ល ។ អញនឹងមិន បង់បោយដើរទៅ / វាសដៃ,ឆ្ការដៃអង្គុយនៅ } ក្នុងបន្លោះផ្ទះ ។

១៩ }
២០ } ។ ល ។ អញនឹងមិនអង្រួនក្បាល ដើរទៅ / អង្គុយនៅ } ក្នុងបន្លោះផ្ទះ ។

២១ }
២២ } ។ ល ។ អញនឹងមិនស្ទឹមបង្កេះ ដើរទៅ / អង្គុយនៅ } ក្នុងបន្លោះផ្ទះ ។

២៣ }
២៤ } ។ ល ។ អញនឹងមិនទទ្រូវក្បាល ដើរទៅ / អង្គុយនៅ } ក្នុងបន្លោះផ្ទះ ។

២៥- ។ ល ។ អញនឹងមិនដើរបំអើតជើងក្នុងបន្លោះផ្ទះ។

២៦- ។ ល ។ អញនឹងមិនអង្គុយត្របោមក្បាលជង្គង់ក្នុងបន្លោះផ្ទះ ។

# ភោជនប្បដិសំយុត្តទី ២ មាន ៣០

១- ភិក្ខុគប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាតដោយគោរព ។

២- ភិក្ខុគប្បីសិក្សាថា កាលទទួលបិណ្ឌបាត, អញនឹងសម្លឹងមើលតែក្នុងបាត្រ ។

៣- ។ ល ។ អញនឹងទទួលសម្ល ឱ្យតែល្មមសមគួរដល់បាយ ។

៤- ។ ល ។ អញនឹងទទួលបិណ្ឌបាត ស្មើតែត្រឹមកណ្ដាប់មាត់បាត្រ ។

៥- ។ ល ។ អញនឹងឆាន់បិណ្ឌបាតដោយគោរព ។

៦- ។ ល ។ កាលឆាន់បិណ្ឌបាត, អញនឹងសម្លឹងមើលតែក្នុងបាត្រ ។

៧- ។ ល ។ អញនឹងឆាន់បិណ្ឌបាត វាចឱ្យស្មើគឺមិនកកាយបាយឱ្យរូងខ្វងកណ្ដាល ឬឱ្យខ្ពស់ ទាប ។

៨- ។ ល ។ អញនឹងឆាន់សម្ល ឱ្យតែល្មមសមគួរដល់បាយ ។

៩- ។ ល ។ អញនឹងមិនឆាន់ប្រមបុះអំពីកំពូលបាយ ។

១០- ។ ល ។ អញនឹងមិនកកាយបាយលុបសម្ល ឬម្ហូបក្រៀម ដើម្បីនឹងឱ្យបានច្រើនជាងគេ ។

១១- ។ ល ។ អញមិនមានជំងឺ នឹងមិនសូមសម្ល ឬម្ហូបក្រៀម ឬបាយ ដើម្បីខ្លួនមកឆាន់ ។

១២- ។ ល ។ អញនឹងមិនសម្លឹងរំពៃមើលបាត្រភិក្ខុឯទៀត ដោយគិតនឹងរិះគន់គេ ។

១៣- ។ ល ។ អញនឹងមិនធ្វើពំនូតបាយឱ្យធំហួសប្រមាណ ។

១៤- ។ ល ។ អញនឹងធ្វើពំនូតបាយឱ្យជាបរិមណ្ឌល គឺឱ្យមូល ។

១៥- ។ ល ។ កាលបើពំនូតបាយនៅមិនទាន់ដល់មាត់ អញនឹងមិនហាមាត់ចាំ ។

១៦- ។ ល ។ អញកាលដែលនឹងឆាន់, នឹងមិនញាត់ម្រាមដៃឱ្យចូលទៅក្នុងមាត់ ។

១៧- ។ ល ។ អញនឹងមិននិយាយទាំងភោជននៅក្នុងមាត់ ។

១៨- ។ ល ។ អញនឹងមិនឆាន់បោះដុំបាយ, ដុំត្រី, ដុំសាច់ ជាដើម ចូលក្នុងមាត់ ។

១៩- ។ ល ។ អញនឹងមិនឆាន់ខាំកាត់ពំនូតបាយមួយកំណាត់ម្ដង ។

២០- ។ ល ។ អញនឹងមិនឆាន់បៀមពំនូតបាយឱ្យទុលប៉ោលទ្បើងដូចជាស្វា ។

២១- ។ ល ។ អញនឹងមិនឆាន់រលាស់ដៃបណ្ដើរ ។

២២- ។ ល ។ អញនឹងមិនឱ្យជ្រុះគ្រាប់បាយរោយរាយក្នុងបាត្រ ឬក្នុងទីនោះ ។

២៣- ។ ល ។ អញនឹងមិនឆាន់លៀនអណ្ដាតឱ្យចេញមកខាងក្រៅ ។

២៤- ។ ល ។ អញនឹងមិនឆាន់ឱ្យឮផ្សប់ៗ ។

២៥- ។ ល ។ អញនឹងមិនឆាន់ឱ្យឮគ្រុកៗ ។

២៦- ។ ល ។ អញនឹងមិនឆាន់លិទ្ធដៃ ។

២៧- ។ ល ។ អញនឹងមិនឆាន់លិទ្ធបាត្រ ឬកោសបាត្រ ។

២៨- ។ ល ។ អញនឹងមិនឆាន់លិទ្ធបបូរមាត់ ។

២៩- ។ ល ។ អញនឹងមិនយកដៃ ដែលប្រឡាក់ដោយអាមិស ទទួលចាប់កាន់ភាជន៍ទឹក ។

៣០- ។ ល ។ អញនឹងមិនបាក់ទឹក ដែលលាងបាត្រមានគ្រាប់បាយក្នុងបន្លោះផ្ទះ ។

## ធម្មទេសនាបដិសំយុត្ត ទី ៣ មាន ១៦

១- ភិក្ខុគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សមិនមានជំងឺ មានឆត្រក្នុងដៃ ។

២- ភិក្ខុគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សមិនមានជំងឺ មានឈើប្រត់ក្នុងដៃ ។

៣- ។ ល ។ មានគ្រឿងសស្ត្រាក្នុងដៃ ។

៤- ។ ល ។ មានអាវុធក្នុងដៃ ។

៥- ។ ល ។ ពាក់ទ្រនាប់ជើងឈើឬទ្រនាប់ជើងស្មៅជាដើម ។

៦- ។ ល ។ ពាក់ស្បែកជើងធ្វើដោយស្បែក ។

៧- ។ ល ។ នៅលើយានមានរថជាដើម ។

៨- ។ ល ។ នៅលើទីដំណេក គឺមនុស្សដេក ។

៩- ។ ល ។ អង្គុយត្របោមក្បាលជង្គង់ ។

១០- ។ ល ។ ជួតឈ្នួតក្បាល ។

១១- ។ ល ។ ទទូរក្បាល ។

១២- ភិក្ខុគប្បីសិក្សាថា អញនឹងមិនអង្គុយផ្ទាល់នឹងផែនដី សម្តែងធម៌ដល់មនុស្សមិនមានជំងឺ អង្គុយលើអាសនៈមានកន្ទេលជាដើម ។

១៣- ។ល។ អញនឹងមិនអង្គុយលើអាសនៈ ទាបសម្តែងធម៌ដល់មនុស្សមិនមានជំងឺ អង្គុយលើអាសនៈខ្ពស់ ។

១៤- ។ ល ។ អញនឹងមិនឈរសម្តែងធម៌ដល់មនុស្សមិនមានជំងឺ ដែលអង្គុយ ។

១៥- ។ ល ។ អញនឹងមិនដើរខាងក្រោយ សម្តែងធម៌ដល់មនុស្សមិនមានជំងឺដើរខាងមុខ ។

១៦- ។ ល ។ អញនឹងមិនដើរក្រៅផ្លូវ សម្តែងធម៌ដល់មនុស្សដែលមិនមានជំងឺដើរក្នុងផ្លូវ ។

## បកិណ្ណកៈទី ៤ មាន ៣

១- ភិក្ខុគប្បីសិក្សាថា អញមិនមានជំងឺ នឹងមិនឈរបន្ទោឧច្ចារៈ ឬបស្សាវៈ ។

២- ។ ល ។ អញមិនមានជំងឺ នឹងមិនបន្ទោឧច្ចារៈ ឬ បស្សាវៈ ឬស្តោះទឹកមាត់ ឬញើសសំបោរដាក់លើវត្ថុមានពណ៌ខៀវ មានដើមឈើ និងគុម្ពស្មៅជាដើម ។

៣- ។ ល ។ អញមិនមានជំងឺ នឹងមិនបន្ទោឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ ឬញើសសំបោរដាក់លើទឹកដែលមិនគួរនឹងធ្វើដូច្នោះបាន ។

សេក្ខិយវត្តទាំង ៧៥ នេះ បើភិក្ខុណាប្រព្រឹត្តកន្លងដោយមិនអើពើ, ដោយមិនមានហេតុនៃអនាបត្តិ, ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

## អធិករណ៍មាន ៤ យ៉ាង

១- សេចក្តីវិវាទថា “សភាវៈនេះ ជាធម៌ជាវិន័យ សភាវៈនេះមិនមែនជាធម៌ មិនមែនជាវិន័យ” ដូច្នេះ ហៅថា វិវាទាធិករណ៍ ។

២- សេចក្ដីចោទប្រកាន់គ្នា ដោយអាបត្តិនោះ ៗ ហៅ-ថា អនុវាទាធិករណ៍ ។

៣- អាបត្តិទាំងពួង ហៅថា អាបត្តាធិករណ៍ ។

៤- កិច្ចដែលសង្ឃគប្បីធ្វើ ហៅថា កិច្ចាធិករណ៍ ។

## អធិករណសមថៈ

ធម៌សម្រាប់រម្ងាប់អធិករណ៍ទាំង ៤ យ៉ាងនេះ ហៅថា អធិករណសមថៈ មាន ៧ យ៉ាងគឺ ៖

១- សេចក្ដីរម្ងាប់អធិករណ៍ ៤ យ៉ាងនោះ អធិករណ៍ណាមួយ ក្នុងទីចំពោះមុខសង្ឃ គឺក្នុងទីប្រជុំសង្ឃ, ចំពោះមុខធម៌ ចំពោះមុខវិន័យ គឺអធិករណ៍នោះ រម្ងាប់ដោយធម៌ដោយវិន័យ ដ៏ត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិនិងពុទ្ធានុញ្ញាត, ចំពោះមុខបុគ្គល គឺគូវិវាទទាំងពីរខាង ឬរូបភិក្ខុដែលទទួលខុស, ហៅ-ថា សម្មុខាវិន័យ ។

២- សេចក្ដីដែលសង្ឃសូត្រប្រកាសឱ្យសម្មតិ ដល់ព្រះអរហន្តថា ជាអ្នកមានសតិពេញបរិបូណ៌ហើយ ដើម្បីនឹងមិន

ឱ្យមានអ្នកណាមួយ ចោទលោកដោយអាបត្តិណាមួយ ហៅ-ថា សតិវិន័យ ។

៣- សេចក្តីដែលសង្ឃសូត្រប្រកាសឱ្យសម្មតិ ដល់ភិក្ខុដែលឆ្កួត ហើយបានជាអំពីឆ្កួតហើយ, ដើម្បីនឹងមិនឱ្យមានអ្នកណាមួយ ចោទដោយអាបត្តិ ដែលភិក្ខុនោះធ្វើក្នុងកាលកំពុងឆ្កួត, ហៅថា អមូឡ្ហវិន័យ ។

៤- សេចក្តីកាត់អាបត្តិ តាមបដិញ្ញា នៃចម្លើយដែលឆ្លើយទទួលតាមពិត ហៅថា បដិញ្ញាតករណៈ ។

៥- សេចក្តីវិនិច្ឆ័យ យកតាមពាក្យនៃមនុស្សច្រើនដែលប្រកបដោយធម៌ជាប្រមាណ ហៅថា យេភុយ្យសិកា ។

៦- សេចក្តីសម្រេចដាក់ទោស ដល់អ្នកដែលមានទោសខុស ហៅថា តស្សបាបិយសិកា ។

៧- សេចក្តីសង្រួបសង្រួម ឱ្យអត់ឱនគ្នាទៅវិញទៅមកទាំងពីរខាងមិនបាច់ជំនុំជម្រះសេចក្តីដើមហៅថា តិណវត្ថារកៈ ។

សិក្ខាបទក្រៅអំពីនេះ ដែលលើកឈ្មោះឡើងជាអាបត្តិ ថុល្លច្ច័យខ្លះ ទុក្កដខ្លះ ទុព្ភាសិតខ្លះនោះ ហៅថា សិក្ខាបទ មិនមានក្នុងបាតិមោក្ខ ។

កុលបុត្រជាភិក្ខុ កាលបើបានសិក្សាចប់សិក្ខាបទដែល មានក្នុងបាតិមោក្ខហើយ, គប្បីសិក្សាសិក្ខាបទ ដែលមិនមាន ក្នុងបាតិមោក្ខតទៅទៀត ។

ចប់បាតិមោក្ខសំវរសីលតែប៉ុណ្ណោះ ។

**ទំព័រនេះ ទទេ**

# ខន្ធវិនយសង្ខេប

គឺ

# ព្រះសិរីសម្មតិវង្ស អែម

បាងហ្វងសាលាបាលីជាន់ខ្ពស់ និងអធិបតីក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

ទំព័រនេះ ទទេ

# សិក្ខាបទដែលមិនមានក្នុងបាតិមោក្ខ

## ថុល្លច្ច័យ

ភិក្ខុកុំគប្បីលះបង់ កុំគប្បីបែកគរុភណ្ឌរបស់សង្ឃ, កុំឱ្យគេធ្វើសត្ថកម្មគឺពុះវះក្នុងទីបង្អៀត, កុំឱ្យគេធ្វើសត្ថកម្មនិងវត្ថិកម្មក្នុងទីប្រមាណ ២ ធ្នាប់ អំពីទីបង្អៀត, កុំឆាន់សាច់មនុស្ស, កុំប្រព្រឹត្តវត្តនិគ្រន្ថតិរ្ថីយមិនស្លៀកសំពត់, កុំស្លៀកដណ្តប់ស្បូវក្រង់, កុំប្រើសំពត់ដែលក្រងទាក់ដោយសំបកឈើ, កុំប្រើសំពត់ដែលធ្វើដោយសក់មនុស្ស, កុំប្រើសំពត់កម្ពលដែលធ្វើដោយរោមកន្ទុយសត្វ, កុំប្រើសំពត់ដែលធ្វើដោយស្លាបមៀម, កុំស្លៀកដណ្តប់ស្បែកខ្លា, កុំប្រើសំពត់ដែលធ្វើដោយសំបកផ្ចិត្ត, កុំពាល់ត្រូវអង្គជាតិសត្វតិរច្ឆានញី, កុំប្រញាប់នឹងធ្វើឧបោសថឬបវារណា ដោយនឹងក្លែងឱ្យភិក្ខុឯទៀតខានបានធ្វើ ។

សេចក្តីបញ្ញត្តិទាំងអស់នេះ បើភិក្ខុប្រព្រឹត្តកន្លង ត្រូវអាបត្តិថុល្លច្ច័យ ។

# ទុក្កដ

ភិក្ខុកុំស្លៀកដណ្ដប់ដូចគ្រហស្ថ, កុំប្រើសំពត់មានពណ៌ខុសផ្សេងៗ មានពណ៌ខៀវលឿងខ្ចីក្រហមប្រាលជាដើម, កុំប្រើចីវរមានខ្នង់វែង មិនបានកាត់ដាច់, កុំប្រើសំពត់មានផ្កាភ្ញីផ្សេងៗ ឬសំពត់ដែលប៉ាក់ស្រែះគូរវិចិត្រផ្សេងៗ, កុំស្លៀកពាក់គ្រឿងប្រដាប់សម្រាប់គ្រហស្ថ មានអាវម្លូកជាដើម, កុំមានតែស្បង់និងចីវរ ដើរចូលទៅក្នុងស្រុក វៀរលែងតែមានហេតុដែលគួរនឹងទុកសង្ឃាដីបាន, បើឥតមានហេតុទេ, គប្បីតម្រួតចីវរនិងសង្ឃាដីជាមួយគ្នា ហើយឃ្លុំទៅ ។ បើមិនមានជំងឺកុំពាក់ស្បែកជើងដើរចូលទៅក្នុងស្រុក, កុំប្រើស្បែកជើងពីរជាន់, កុំប្រើទ្រនាប់ជើងឈើ, ទ្រនាបជើងស្មៅ, ស្បែកជើងផ្ទាត់, ស្បែកជើងឃ្លុប, ស្បែកជើងប៉ាក់វិចិត្រដោយពណ៌ផ្សេងៗ និងស្បែកជើងដែលធ្វើដោយស្បែកជាអកប្បិយៈ មានស្បែកខ្លាស្បែកភេជាដើម ។ មិនមានជំងឺកុំផាត់មុខលាបខ្លួនដោយគ្រឿងផាត់គ្រឿងលាបផ្សេងៗ, កុំឆ្លុះស្រមោលមុខមើលក្នុងកញ្ចក់ឬក្នុងទឹក, កុំឱ្យគេកាត់សក់ កាត់ពុកមាត់ ពុកចង្កា ។

កុំពាក់គ្រឿងប្រដាប់ មានកងនិងបិញ្ចៀនជាដើម, កុំឱ្យគេដកសក់ស្កូវ, កុំសម្លឹងមើលនិមិត្តស្រ្តី ។ កាលងូតទឹក, កុំដុសខ្លួននឹងឈើផ្សេងៗ ឬនឹងរបស់ដែលមិនគួរដុស, កុំយកខ្នងនិងខ្នងត្រដុសគ្នា ។ កុំព្យួរបាត្រនិងគ្រែ ឬតាំង ឬក្រប, កុំយករបស់ដែលជាដែលដាក់ក្នុងបាត្រ, កុំយកបាត្រទៅទុកទាំងទទឹក ទាំងសើម ត្រូវជូតត្រូវហាលសិន កាលហាលបាត្រកុំហាលឱ្យយូរពេក, កុំអង្គុយលើអាសនៈវែង ជាមួយនឹងស្ត្រីនិងបណ្ឌកនិងឧភតោព្យញ្ជនកៈ, កុំអង្គុយលើគ្រែតាំងជាមួយនឹងអសមានាសនិកបុគ្គល គឺភិក្ខុមានអាសនៈមិនស្មើគ្នា តាំងពីបាស់ជាងគ្នា ៣ វស្សាឡើងទៅ, កុំអង្គុយ កុំដេកលើទីអង្គុយទីដេកដែលធំខ្ពស់ គឺគ្រែតាំងមានជើងខ្ពស់ហួសប្រមាណ និងពូកញាត់ដោយគរដោយសំឡី និងកម្រាលដែលធ្វើដោយរោមសត្វដ៏វិចិត្រផ្សេងៗ កុំប្រើខ្នើយធំវែងប្រមាណកន្លះកាយ, អាសនៈដែលគេក្រាលហើយ បើមិនទាន់ពិចារណាកុំអាលអង្គុយ, កុំដេកលើដំណេកមានរំយោលផ្កា, កុំហាមអាសនៈភិក្ខុចាស់ កុំសំពះអវន្ទិយបុគ្គល ១០ ជំពូក គឺភិក្ខុដែលបានឧបសម្បទា

ក្រោយខ្លួន ១, អនុបសម្ប័ន្ន ១, ភិក្ខុដែលមានសំវាសផ្សេងគ្នា សូម្បីចាស់វស្សាជាង តែជាអធម្មវាទី ១, មាតុគ្រាម ១, បណ្ឌក ១, បរិវាសិកភិក្ខុ ១, មូលាយប្បដិកស្សនារហភិក្ខុ ១, មានត្តារហភិក្ខុ ១, មានត្តចារិកភិក្ខុ ១, អព្ភានារហភិក្ខុ ១ ។ កុំយកសេនាសនៈរបស់សង្ឃ ដែលមាននៅក្នុងទីឯទៀត ទៅទុកប្រើនៅទីដទៃ, កុំបង្គាប់ភិក្ខុដែលចាស់មិនទាន់រួបឱ្យក្រោក, កុំបណ្តេញភិក្ខុឈឺ ឱ្យក្រោកចាកអាសនៈ, គប្បីបម្រើថែទាំភិក្ខុឈឺ, បើមានជំងឺបន្តិចបន្តួច កុំហួងហែងសេនាសនៈ, កុំហួងហែងអាសនៈរបស់សង្ឃ អស់កាលទាំងពួង, ម្នាក់ឯងកុំហួងហែងទីកន្លែងពីរបី, កុំទទួល កុំឆាន់ត្រីស្រស់ សាច់ឆៅ, កុំឆាន់ឧទ្ទិស្សមំសៈ គឺសាច់ដែលគេពិឃាតចំពោះសមាធម្មិកទាំង ៥ ណាមួយ, កុំរៀនឬបង្រៀនតិរច្ឆានវិជ្ជា ។ បើមានភិក្ខុជាថេរៈនៅនោះហើយ បើព្រះថេរៈមិនទាន់និមន្តឱ្យសម្តែង កុំសម្តែងធម៌ក្នុងទីប្រជុំ កុំសូត្រធម៌រលាក់រលែក ដោយសំឡេងវែងៗដូចសំឡេងច្រៀង, មិនមានសំពត់តម្រងទឹកកុំដើរដំណើរ, បើភិក្ខុឯទៀតត្រូវការខ្ចីសំពត់តម្រងទឹកកុំមិនឱ្យ, កុំធ្វើសទ្ធាទេយ្យ,

វត្ថុ គឺវត្ថុដែលគេប្រគេនដោយសទ្ធាឱ្យធ្លាក់ទៅ, កុំឱ្យអនាមដ្ឋ-បិណ្ឌបាត ដល់គ្រហស្ថ វៀរលែងតែបុគ្គលដែលគួរឱ្យ, កុំធ្វើពេទ្យ, កុំធ្វើជាទូតនាំសំបុត្រ, កុំសង្គ្រោះត្រកូលដោយឱ្យផ្កាឈើផ្លែឈើជាដើម, កុំប្រព្រឹត្តអនាចារ មានដាំឈើផ្កាជាដើម, កុំលេងល្បែងផ្សេងៗមានបត្រង្គជាដើម, កុំប្រមៀលដុំថ្មដុំដីលេង, កាលបើមិនមានហេតុ កុំឡើងដើមឈើ, កុំដុតព្រៃ, កុំប្រើអ-កប្បិយបរិក្ខារផ្សេងៗ មានបាត្រឈើ បាត្រស្ពាន់ និងបាត្រដែលមានពណ៌ខៀវ ពណ៌ខ្មៅរលើបជាដើម, កុំប្រើឈើស្ទន់វែងជាង ៨ ធ្នាប់ឬខ្លីជាង ៤ ធ្នាប់, កុំបបួល កុំដឹកនាំបព្វជិតផងគ្នាក្នុងកម្មមិនគួរ, កុំជ្រលក់ចីវរដោយទឹកជ្រលក់ជាអកប្បិយៈផ្សេងៗ មានទឹករមៀត ទឹកស្បែង ទឹកឃ្លេ ទឹកព្រហូតជាដើម ។ រូបភាពស្ត្រី គ្រឿងប្រដាប់ស្ត្រី ស្រូវ ៧ ប្រការ រតនវត្ថុ ១០ ប្រការ មានកែវមណី កែវពៃទូរ្យ កែវប្រពាលមាសប្រាក់ជាដើម, គ្រឿងភ្លេងតន្ត្រីទាំងពួង, ផ្លែឈើដែលនៅជាប់នឹងដើម, គ្រឿងសស្ត្រាវុធទាំងពួង មានដាវ លំពែងកាំភ្លើងជាដើម របស់ទាំងអស់នេះកុំយកដៃពាល់, កុំចាប់

ពាល់ភាជន៍ដាក់របស់ ដែលគេមិនទាន់ប្រគេន ។ ភិក្ខុអាគន្តុកៈ កាលនឹងចូលទៅវត្តឯទៀត ត្រូវដោះស្បែកជើង តម្លោះឆត្រ ។ នៅក្នុងរោងឆាន់ កុំអង្គុយជ្រៀតបៀតភិក្ខុចាស់, កុំហាមអាសនៈភិក្ខុខ្ចី, កុំខ្ពុរមាត់ឱ្យខ្ទាត ប្រឡាក់ស្បង់ចីពរភិក្ខុដែលអង្គុយជិត ។ ទៅបិណ្ឌបាត កុំចូលចេញដោយប្រញាប់ , ប្រញាល់រូសរាន់, កុំឈរឱ្យឆ្ងាយពេក ជិតពេក, កុំទទួលបង្ហាន់បិណ្ឌបាត ជ្រៀតជ្រែកដណ្ដើមគ្នា, កុំមើលមុខទាយកអ្នកដាក់បាត្រ ។ កាលនឹងជម្រះសម្អាតសេនាសនៈ, កុំគោះបោករលាស់ជិតអ្នកដទៃ ជិតកុដិ ជិតទឹកឆាន់ ទឹកប្រើ, កុំគោះបោករលាស់ក្នុងទីខាងលើខ្យល់ ។ នៅក្នុងកុដិជាមួយនឹងភិក្ខុចាស់ បើមិនបានប្រាប់លោកជាមុន កុំបង្រៀនឧទ្ទេស ឬ បរិបុច្ឆា, កុំស្វាធ្យាយ, កុំសម្ដែងធម៌, កុំអុជប្រទីប, លត់ប្រទីប, បើកបិទទ្វារបង្អួច, វៀរលែងតែលោកបានអនុញ្ញាតជាស្រេចថា មិនបាច់ប្រាប់លោកទៀតឡើយ, កុំដើរឱ្យប៉ះភិក្ខុចាស់នឹងជាយចីពរ ។ កុំចូលបង្គន់ប្រកាន់មុនក្រោយ តាមលំដាប់វស្សា, កុំចូលបង្គន់ដោយរហ័សរូសរាន់ពេក, បើឃើញទ្វារបង្គន់បិទ

ត្រូវគ្រហែម ឬគោះទ្វារជាសម្គាល់សិន, កុំសើយស្បង់ពីចម្ងាយចូលទៅ, កុំប្រឹងរមាត់ឱ្យឮខ្លាំង, កុំបន្ទោឧច្ចារៈ ខុសប្រហោងបង្គន់, កុំបន្ទោបស្សាវៈ ខុសទ, កុំស្តោះទឹកមាត់ ឬ ញើសសំបោរក្នុងបង្គន់, កុំកិតនឹងឈើមុត ឬឈើពុក កុំបោលឈើកិតក្នុងរណ្ដៅបង្គន់ កាលបើទឹកមានកុំមិនលាង , កុំលាងជម្រះដោយទឹកឱ្យឮសូរខ្លាំង, កុំទុកទឹកនៅសល់ ក្នុងបំពង់ជម្រះ, បើបង្គន់ប្រឡាក់ ឬមានសម្រាម ត្រូវលាង ត្រូវបោសសម្អាត កុំបេញពីបង្គន់ដោយប្រញាប់ប្រញាល់, កុំទៅទាំងសើយស្បង់ចេញមក ។ កុំទៅមើល ទៅស្ដាប់ល្បែងរបាំងច្រៀងរាំភ្លេងប្រគំផ្សេងៗ, មិនក្រវាត់វត្ថពន្ធបង្កេះ កុំទៅកាន់ស្រុក, មានបាត្រនៅក្នុងដៃ កុំប្រានសន្ទះទ្វារ, កុំដេកលើគ្រែ លើតាំង លើកម្រាលជាមួយគ្នា, កុំធាន់ខ្នើមសុទ្ធតែមានលាយអ្វី, ជើងមិនទាន់លាង ជើងទទឹក ជើងពាក់ស្បែកជើង កុំដើរជាន់លើទីសេនាសនៈ មានគ្រែតាំងនិងកម្រាលជាដើម និងទីផ្ទៃដែលគេធ្វើបរិកម្មលាបលនវិចិត្រផ្សេងៗ, កុំផ្អែកនឹងជញ្ជាំង ឬកំពែងដែលគេធ្វើបរិកម្មឬចិត្តកម្ម គឺលាបកំបោរលាបថ្នាំ ឬគូរគំនូរ, កុំ

ស្តោះទឹកមាត់លើផ្ទៃដែលគេធ្វើបរិកម្ម ទីសេនាសនៈរបស់សង្ឃ ដែលស្អាតបរិសុទ្ធ ត្រូវក្រាលកម្រាលរបស់ខ្លួនលើសិនហើយ សឹមដេក ។ កុំទុកសក់ឱ្យវែងជាងពីរធ្នាប់ ឬយូរជាងពីរខែ, កុំទុកពុកមាត់ពុកចង្កា រោមប្រមុះ ក្រចកឱ្យវែង, កុំខាត់ក្រ-ចក ។ មិនទាន់ពិចារណាមុន កុំឆាន់សាច់អ្វីៗ, កុំឆាន់សាច់ដំរី សាច់សេះ សាច់ឆ្កែ សាច់ពស់ សាច់សីហៈ សាច់ខ្លាធំ សាច់ខ្លាដំបង សាច់ខ្លាឃ្មុំ សាច់ឆ្កែព្រៃ ។

សេចក្ដីបញ្ញត្តិទាំងអស់នេះ បើភិក្ខុប្រព្រឹត្តកន្លង ត្រូវអាបត្តិទុក្កដ ។

## ទុព្ភាសិត

ភិក្ខុមិនមានបំណងនឹងជេរឱ្យបានសេចក្ដី អប្បិយសគ្រាន់តែមានបំណងនឹងពោលបំអកឡកលេងនឹងឧបសម្បន្ន គឺភិក្ខុផងគ្នាក្ដី ឬពោលបញ្ចិតបញ្ចៀងប្រៀបប្រាយដោយអក្កោសវត្ថុ ១០ យ៉ាង មានជាតិជាដើមឯណាមួយ ដែលមានក្នុងបាលីក្ដី មិនមានក្នុងបាលីក្ដី ដូចពាក្យមានដើមថា "លោកជាក្សត្រិយ៍ អ្នកជាព្រាហ្មណ៍, ចៅឯងជាតិរច្ឆាន, ឯងជាអ្នកប្រាជ្ញ, ឯងជា

ហោរ” គឺពោលតាមទំនងនៃពាក្យបំអកឡកលេង ដែលតែង
មានយ៉ាងណានោះ, ដូច្នេះ ត្រូវអាបត្តិទុក្កដសិតរាល់មាត់ ។

អំពីនេះនឹងសម្ដែងនូវបំនួនសិក្ខាបទនៃភិក្ខុនី ដែលមាន
ក្នុងភិក្ខុនីវិភង្គ ក្នុងគម្ពីរបាចិត្តិយៈ និងខន្ធកៈ ២២ ដែលមានក្នុង
ខន្ធកវិន័យក្នុងគម្ពីរមហាវគ្គនិងចូឡវគ្គនិងឈ្មោះវារៈ ទាំង ១៦
ដែលមានក្នុងគម្ពីរបរិវារ ជាសេចក្ដីសង្ខេប ដើម្បីជាផ្លូវសិក្សា
នៃកុលបុត្រទាំងឡាយ ដែលជាសិក្ខាកាម ជាប្រយោជន៍នឹងឱ្យ
បានដឹងរបៀបនៃវិន័យពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតក្នុងសង្ឃ-
កម្ម និងករណីយាករណីយកិច្ច ដែលមានក្នុងគម្ពីរវិនយ-
បិដក ។

## ឧប្បត្តិហេតុនៃភិក្ខុនី

នឹងសម្ដែងអំពី ឧប្បត្តិហេតុ គឺដើមហេតុដែលកើតមាន
ភិក្ខុនី តាមន័យដែលមានក្នុងភិក្ខុនិក្ខន្ធកទី ២០ ក្នុងគម្ពីរ
ចូឡវគ្គ ដោយសង្ខេបជាមុន ។

ដំណើរសេចក្ដីថា កាលព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ទ្រង់
បានត្រាស់បរមាភិសម្ពោធិញ្ញាណ បានបំពេញពុទ្ធកិច្ចផ្សាយ

ធម៌វិន័យ ព្រះពុទ្ធសាសនា បានផ្សាយទូលាយទៅក្នុងលោកហើយ, កាលដែលព្រះបាទសិរីសុទ្ធោទនជាពុទ្ធបិតា ទ្រង់បរិនិព្វានហើយ, ព្រះនាងមហាបជាបតិគោតមី ជាព្រះមាតុច្ឆានៃព្រះបរមសាស្ដា មានព្រះទ័យចង់សូមឧបសម្បទា ជាភិក្ខុនី, ហើយបានចូលទៅសូមបព្វជ្ជា ឧបសម្បទា បំពោះនឹងព្រះសាស្ដាអស់វារៈ ៣ ដង, ព្រះអង្គមិនព្រមអនុញ្ញាតឱ្យ ដោយទ្រង់មានព្រះតម្រិះឃើញកាលទៅខាងមុខថា ព្រហ្មចរិយធម៌របស់មាតុគ្រាមដែលបានបព្វជ្ជា ឧបសម្បទាហើយនោះ នឹងមិនបានតាំងនៅអស់កាលយូរឡើយ ព្រោះមាតុគ្រាមប្រកបដោយធម៌ជាគ្រឿងសៅហ្មងច្រើន នឹងប្រតិបត្តិឱ្យសព្វគ្រប់តាមធម៌វិន័យ ដែលព្រះអង្គនឹងត្រូវបញ្ញត្តិ ឱ្យគួរដល់ភេទនៃភិក្ខុនីនោះ បានដោយកម្រណាស់ ។ លុះតមកខាងក្រោយ ព្រះអានន្ទបានជួយទូលអង្វរអស់វារៈ ៣ ដងទៀត, ព្រះសម្មាសម្ពុទ្ធក៏នៅតែមិនព្រម,ព្រះអានន្ទទូលសួរថា “មាតុគ្រាមបើបួសហើយ នឹងអាចធ្វើគុណវិសេសគឺមគ្គផល ឱ្យសម្រេចបានឬទេ?” ព្រះអង្គទ្រង់ត្រាស់តបថា “អាចនឹងធ្វើគុណវិសេស ឱ្យសម្រេចបាន” ។ ព្រះអានន្ទ

ក៏ទូលអង្វរ សូមឱ្យព្រះអង្គអនុញ្ញាតប្រទានបព្វជ្ជា ឧបសម្បទា ដល់ព្រះនាងមហាបជាបតិគោតមី ។ ព្រះសាស្ដាក៏ទ្រង់ព្រមអនុញ្ញាតឱ្យព្រះនាងមហាបជាបតិគោតមី បានឧបសម្បទាជាភិក្ខុនី ដោយព្រះនាងអាចទទួលប្រព្រឹត្តនូវគរុធម៌ ៨ ប្រការ ជាមុន ជាងភិក្ខុនីទាំងឡាយ ក្នុងព្រះពុទ្ធសាសនានេះ ។

ក្នុងលំដាប់នោះព្រះបរមគ្រូក៏ទ្រង់អនុញ្ញាតឱ្យភិក្ខុសង្ឃ ឱ្យឧបសម្បទាដល់នាងសាកិយានីទាំងឡាយ ដែលជាបរិវារនៃព្រះមហាបជាបតិគោតមី ដោយញត្តិចតុត្ថកម្មវាចា ។ លុះដល់កាលជាខាងក្រោយតមកទៀត ទ្រង់អនុញ្ញាតឱ្យសាកសួរអន្តរាយិកធម៌ ២៤ ប្រការ បំពោះនឹងស្ត្រីទាំងឡាយ ដែលចូលមកសូមឧបសម្បទា ក្នុងកណ្ដាលជំនុំភិក្ខុសង្ឃ, ស្ត្រីទាំងឡាយនោះកើតមានសេចក្ដីអៀនខ្មាស់, ព្រះអង្គក៏អនុញ្ញាតឱ្យភិក្ខុនីសង្ឃសាកសួរអន្តរាយិកធម៌ ក្នុងសំណាក់ភិក្ខុនីសង្ឃ ហើយឱ្យឧបសម្បទាម្ដងជាមុនរួចហើយ ទើបឱ្យនាំមកទទួលឧបសម្បទា ក្នុងសំណាក់ភិក្ខុសង្ឃៗ មិនបាច់សាកសួរអន្តរាយិកធម៌ទៀតឡើយ ត្រូវឱ្យឧបសម្បទាដោយញត្តិចតុត្ថកម្មវាចាតែម្ដង ។

ភិក្ខុនីដែលបានឧបសម្បទា អំពីសំណាក់ភិក្ខុនីសង្ឃតែ ១ ពួក ហៅថា "ឯកតោឧបសម្បន្នា" មិនទាន់រាប់បញ្ចូលជាភិក្ខុនីពេញទីក្នុងសិក្ខាបទឡើយ, ភិក្ខុនីដែលបានឧបសម្បទាអំពីសំ-ណាក់សង្ឃទាំង ២ ពួកហើយ ហៅថា "ឧភតោឧបសម្បន្នា" រាប់បញ្ចូលជាភិក្ខុនីពេញទីក្នុងសិក្ខាបទ ។ ភិក្ខុនីទាំងឡាយនោះ មានកិច្ចវត្តប្រតិបត្តិនឹងសង្ឃកម្មទាំងពួង ប្រហែលគ្នានឹងភិក្ខុក៏មាន ផ្សេងច្រើនជាងភិក្ខុ តឹងជាងភិក្ខុទៅទៀត ក៏មាន ព្រោះហេតុនោះ បានជាភិក្ខុនី មិនអាចនឹងតាំងសង្ឃមណ្ឌលឱ្យឋិតនៅវែងឆ្ងាយមកបាន ។

## ចំនួនសិក្ខាបទនៃភិក្ខុនី

សិក្ខាបទនៃភិក្ខុនី ដែលមានក្នុងភិក្ខុនីបាតិមោក្ខ រួមទាំងអធិករណសមថ ៧ ផង បាន ៣១១ សិក្ខាបទគឺ បារាជិក ៨, សង្ឃាទិសេស ១៧, និស្សគ្គិយបាចិត្តិយ ៣០, សុទ្ធិកបាចិត្តិយ ១៦៦, បាដិទេសនីយ ៨, សេក្ខិយវត្ត ៧៥, អធិករណសមថ ៧ រួមត្រូវជា ៣១១ សិក្ខាបទ ។

# ខន្ធកៈ ២២

# ក្នុងគម្ពីរមហាវគ្គ មានខន្ធកៈ ១០

១- **មហាខន្ធក** សម្តែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត រឿងបព្វជ្ជានិងឧបសម្បទា នៃកុលបុត្រ និងបុគ្គលដែលគួរបំបួសនិងមិនគួរបំបួស និងវិធីកាន់យកនិស្ស័យក្នុងសំណាក់ឧបជ្ឈាយ៍ ឬ អាចារ្យ នៃភិក្ខុសាមណេរជាដើម (ខន្ធកៈនេះនឹងហៅថា “បព្វជ្ជាខន្ធកៈ” ដូច្នេះវិញក៏បាន) ។

២- **ឧបោសថក្ខន្ធក** សម្តែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត រឿងឧបោសថនៃភិក្ខុសង្ឃ ប្រកបដោយអង្គ ៩ និងឧបោសថកម្ម ៤ យ៉ាង និងទីអាវាសដែលគួរធ្វើ និងទីដែលមិនគួរធ្វើឧបោសថកម្ម និងវិធីសម្មតិរោងឧបោសថ និងវិធីសម្មតិបងសីមា និងដកសីមាជាដើម ។

៣- **វស្សូបនាយិកក្ខន្ធក** សម្តែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត រឿងចូលវស្សានៃភិក្ខុសាមណេរ និងអនុញ្ញាតទីសេនាសនៈ ដែលគួរចូលវស្សា និងមិនគួរចូល និងអនុញ្ញាតសត្តាហកិច្ចជាដើម ។

៤- **បវារណាក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតរឿងបវារណាកម្ម ដោយស្ថាន ៣ យ៉ាងគឺ ដោយឃើញ ឬដោយឮ ឬដោយរង្កៀស និងអនុញ្ញាតវិធីបវារណា ៤ យ៉ាងគឺ តេវាចិកាបវារណា ១, ទ្វេវាចិកាបវារណា ១, ឯកវាចិកាបវារណា ១, សមានវស្សិកាបវារណា ១ ជាដើម ។

៥- **បម្មក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិនិងពុទ្ធានុញ្ញាតរឿងប្រើស្បែកជើង និងអនុញ្ញាតយានជំនិះ ដល់ភិក្ខុឈឺ និងបទេសប្បញ្ញត្តិ ៤ យ៉ាង និងអនុញ្ញាតឱ្យប្រើកម្រាលដែលធ្វើដោយស្បែកសត្វ ៣ ពួក និងបញ្ញត្តិ មិនឱ្យប្រើគ្រឿងប្រើប្រាស់ដែលធ្វើដោយស្បែកសត្វជាអកប្បិយៈផ្សេងៗ ដែលមិនគួរជាសមណបរិក្ខារជាដើម ។

៦- **ភេសជ្ជក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត រឿងភេសជ្ជៈដែលគួរនិងមិនគួរ ដល់ភិក្ខុសាមណេរ និងបញ្ញត្តិមិនឱ្យឆាន់សាច់ ១០ ប្រការ និងឧទ្ទិស្សមំសៈ និងអនុញ្ញាត ឱ្យភិក្ខុសាមណេរ ត្រេកអរចំពោះបច្ចុប្បច្ច័យដែលកើតអំពីរូបិយៈជាដើម ។

៧- **កឋិនក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត រឿងក្រាលកឋិន និងអនុមោទនាកឋិន និងសហជាតធម៌ ១៥ ប្រការ គឺអានិសង្ស ៥ មាតិកា ៨ បលិពោធ ២ និងអនត្ថ-តាការ គឺអាការដែលមិនគួរក្រាល ២៤ យ៉ាង និងអត្ថតាការ គឺអាការដែលគួរក្រាល ១៧ យ៉ាងជាដើម ។

៨- **ចីវរក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត រឿងចីវរ និងការទទួលសំពត់ ដែលទាយកប្រគេន និង កំណើតសំពត់ ៦ យ៉ាង និងសំពត់ដែលគួរប្រើ និងមិនគួរប្រើ និងសំពត់ដែលមានពណ៌គួរប្រើ និងមិនគួរប្រើ និងទឹកជ្រលក់ ៦ យ៉ាង ជាដើម ។

៩- **ចម្បេយ្យក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត រឿងលក្ខណៈសង្ឃកម្ម ដែលប្រកបដោយធម៌ និងមិនប្រកប ដោយធម៌ និងការកសង្ឃ ៥ ពួក ដែលគួរដល់សង្ឃកម្ម នោះៗ ជាដើម ។

១០- **កោសម្ពិកក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធា-នុញ្ញាត រឿងសាមគ្គីឧបោសថ និងសាមគ្គីបវារណា ដោយហេតុ

ភិក្ខុទាំងឡាយ ក្នុងនគរកោសម្ពី កើតវិវាទទាស់ទែងគ្នាជាដើម (ខន្ធកនេះនឹងហៅថា “កោសម្ពិកក្ខន្ធកៈ” ដូច្នេះវិញក៏បាន) ។

## ក្នុងគម្ពីរចូឡវគ្គ មានខន្ធកៈ ១២

**១១- កម្មក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតកម្ម ៥ យ៉ាងគឺ តជ្ជនីយកម្ម ១, និយសកម្ម ១, បព្វាជនីយ-កម្ម ១, បដិសារណីយកម្ម ១, ឧក្ខេបនីយកម្ម ១ ដែលសង្ឃគប្បីធ្វើ ដល់ភិក្ខុអ្នកប្រព្រឹត្តខុសទាស់នឹងពុទ្ធប្បញ្ញត្តិនោះ ៗ ជាដើម ។

**១២- បរិវាសិកក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធា-នុញ្ញាត វិធីប្រព្រឹត្តវត្ត ៩៤ យ៉ាង សម្រាប់ភិក្ខុ ដែលត្រូវគរុកា-បត្តិ គឺអាបត្តិសង្ឃាទិសេស ហើយធ្វើបរិវាសកម្មជាដើម ។

**១៣- សមុច្ចយក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធា-នុញ្ញាតវុដ្ឋានវិធី គឺវិធីចេញចាកគរុកាបត្តិ ដោយបរិវាសកម្ម ៣ យ៉ាង ឯណាមួយ និងវិធីប្រព្រឹត្តមានត្ត អស់ ៦ រាត្រី និងអព្ភានកម្មជាដើម ។

១៤- **សមថក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតសមថៈ ៧ យ៉ាង មានសម្មុខាវិន័យជាដើម សម្រាប់រម្ងាប់អធិករណ៍ ៤ យ៉ាង មានវិវាទាធិករណ៍ជាដើម ។

១៥- **ខុទ្ទកវត្ថុក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត្ត ជាសេចក្ដីប្រតិបត្តិតូចៗ មានការងូតទឹក និងការប្រើប្រាស់គ្រឿងបរិក្ខារ ដែលគួរនិងមិនគួរ ដល់សមណសារូបជាដើម ។

១៦- **សេនាសនក្ខន្ធក** សម្ដែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតសេនាសនៈ គឺ វិហារ, អឌ្ឍយោគ, ប្រាសាទ, គុហា, រោងជែរ និងគ្រឿងទព្វសម្ភារៈផ្សេងៗ ដែលគួរដល់កិច្ចនោះៗ និងបញ្ញត្តិ ហាមមិនឱ្យភិក្ខុបែក មិនឱ្យលះគរុភណ្ឌរបស់សង្ឃជាដើម ។

១៧- **សង្ឃភេទក្ខន្ធក** សម្ដែងអំពីរឿងទេវទត្ត ដែលព្យាយាមបំបែកសង្ឃ និងអំពើបំបែកសង្ឃនៃទេវទត្ត និងលក្ខណៈសង្ឃភេទកម្មមានអង្គ ៩ និងសេចក្ដីសាមគ្គីនៃសង្ឃជាដើម ។

១៨- **វត្តក្ខន្ធក** សម្តែងអំពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតវត្ត ដែលភិក្ខុសាមណេរគប្បីប្រព្រឹត្ត ដើម្បីនឹងសម្តែងនូវសេចក្តីគោរពដល់គ្នានិងគ្នាខ្លះ, ជាវត្តប្រតិបត្តិដ៏សមគួរដល់សមណ-សារូបខ្លះ រួមទាំងអស់ ១៤ វត្ត មានអាគន្តុកវត្តជាដើម ។

១៩- **បាតិមោក្ខដ្ឋបនក្ខន្ធក** សម្តែងអំពីពុទ្ធប្បញ្ញត្តិនិងពុទ្ធានុញ្ញាត ដំណើរឃាត់មិនឱ្យសម្តែងបាតិមោក្ខ បំពោះភិក្ខុ ដែលប្រកបដោយអាបត្តិ និងសម្តែងនូវអច្ឆរិយព្ភុតធម៌ ៨ យ៉ាងនៃមហាសមុទ្រ ប្រៀបដោយសេចក្តីស្អាតបរិសុទ្ធ នៃធម៌វិន័យជាដើម ។

២០- **ភិក្ខុនីខន្ធក** សម្តែងអំពីឧប្បត្តិហេតុនៃភិក្ខុនី និងពុទ្ធានុញ្ញាតបព្វជ្ជាឧបសម្បទានៃភិក្ខុនី និងពុទ្ធប្បញ្ញត្តិសម្រាប់ពួកភិក្ខុនីប្រតិបត្តិ មានគរុធម៌ ៨ ប្រការជាដើម ។

២១- **បញ្ចសតិកក្ខន្ធក** សម្តែងអំពីរឿងបឋមសង្គាយនា ដែលព្រះអរហន្តទាំងឡាយ ៥០០ អង្គ មានព្រះមហាកស្ស-បត្ថេរជាដើម ប្រជុំគ្នា ធ្វើក្នុងកាលដែលព្រះសម្មាសម្ពុទ្ធបរិព្វាន

ហើយ, បើរាប់ឈ្មោះខែបានបួនខែ, បើរាប់ជាចំនួនថ្ងៃ បាន តែត្រឹម ៣ ខែ, រម្ងាប់ពាក្យបរប្បវាទ ដែលសុភទ្ទភិក្ខុពោល ឡើងជាមន្ទិលក្នុងព្រះពុទ្ធសាសនា ។

**២២- សត្តសតិកក្ខន្ធក** សម្ដែងអំពីរឿងទុតិយសង្គាយ-នាដែលព្រះអរហន្តទាំងឡាយ ៧០០ អង្គ មានព្រះសព្វកាមិត្ថេរ ជាដើម ប្រជុំគ្នា ធ្វើក្នុងកាលពុទ្ធសករាជបាន ១០០ ឆ្នាំសេស វិនិច្ឆ័យវត្ថុ ១០ ប្រការ ដែលវជ្ជីបុត្តកភិក្ខុទាំងឡាយ សម្ដែង ឡើង (១០ ប្រការនោះនឹងមានសម្ដែងទៅខាងមុខ) ។

ក្នុងគម្ពីរបរិវារៈ មានសេចក្ដីសម្ដែងអំពីពុទ្ធប្បញ្ញត្តិ និង ពុទ្ធានុញ្ញាតផ្សេងៗ ដែលមានក្នុងគម្ពីរវិន័យបិដកទាំង ៤ ខាង ដើម គឺគម្ពីរអាទិកម្មខ្លះ បាចិត្តិយខ្លះ មហាវគ្គខ្លះ ចូឡវគ្គខ្លះ ដែលមានក្រៅអំពីគម្ពីរទាំង ៤ នោះខ្លះ ជាសេចក្ដីរួបរួមដោយ តាំងជាពាក្យបុច្ឆាវិសជ្ជនាខ្លះ ជារបៀបធម៌ដោយជំពូក ៗ ខ្លះ ជាបកិណ្ណកកថាខ្លះ មានសម្ដែងអំពីវារៈ ១៦ ក្នុងភិក្ខុវិភង្គ ជាដើម ។

# វារៈ ១៦ ក្នុងភិក្ខុវិភង្គ

១- **កត្ថប្បញ្ញត្តិវារ** សម្ដែងពីសេចក្ដីបុច្ឆាសួរអំពីទីដែលបញ្ញត្ត, អំពីបុគ្គល, អំពីហេតុដែលកន្លង នៃសិក្ខាបទទាំងពួងមានបឋមបារាជិកជាដើមថា "ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា, ប្រារព្ធនឹងបុគ្គលឈ្មោះអ្វី, ហេតុដូចម្ដេចបានជាបញ្ញត្ត?, និងពាក្យវិសជ្ជនា ឆ្លើយតបតាមហេតុ នៃសេចក្ដីបុច្ឆានោះ ៗ ។

២- **កតាបត្តិវារ** សម្ដែងពីសេចក្ដីបុច្ឆាសួរអំពីចំនួននៃអាបត្តិ នៃភិក្ខុដែលប្រព្រឹត្តកន្លងសិក្ខាបទទាំងពួង មានបឋម-បារាជិកជាដើមថា "កាលបើភិក្ខុប្រព្រឹត្តកន្លងសិក្ខាបទនោះៗ តើនឹងត្រូវអាបត្តិអ្វី?" និងពាក្យវិសជ្ជនា ឆ្លើយតបតាមហេតុ នៃសេចក្ដីបុច្ឆានោះ ៗ ។

៣- **វិបត្តិវារ** សម្ដែងពីសេចក្ដីបុច្ឆាសួរអំពីវិបត្តិនៃភិក្ខុដែលប្រព្រឹត្តកន្លងសិក្ខាបទទាំងពួងថា "ភិក្ខុដែលប្រព្រឹត្តកន្លងសិក្ខាបទនោះៗ ក្នុងវិបត្តិទាំង ៤ យ៉ាង នឹងរាប់បញ្ចូលក្នុង

វិបត្តិណាខ្លះ?” , និងពាក្យវិសជ្ជនា ឆ្លើយតបតាមហេតុនៃសេចក្តីបុច្ឆានោះៗ ។

៤- **សង្គហិតាវារ** សម្តែងពីសេចក្តីបុច្ឆាសួរអំពីសិក្ខាបទទាំងពួងដែលភិក្ខុប្រព្រឹត្តកន្លងហើយថា “អាបត្តិនោះ ៗ ដែលភិក្ខុត្រូវហើយនោះ ក្នុងអាបត្តិទាំង ៧ កង នឹងរាប់បញ្ចូលក្នុងអាបត្តិកងណាខ្លះ?” និងពាក្យវិសជ្ជនា ឆ្លើយតបតាមហេតុនៃសេចក្តីបុច្ឆានោះ ៗ ។

៥- **សមុដ្ឋានវារ** សម្តែងពីសេចក្តីបុច្ឆាសួរអំពីទីកើតនៃដំណើរ ដែលភិក្ខុប្រព្រឹត្តកន្លងហើយ នូវសិក្ខាបទទាំងពួងថា “អាបត្តិទាំងនោះ ដែលភិក្ខុត្រូវហើយ ក្នុងសមុដ្ឋានទាំង ៦ យ៉ាង កើតដោយសមុដ្ឋានប៉ុន្មានយ៉ាង?” និងពាក្យវិសជ្ជនា ឆ្លើយតបតាមហេតុនៃសេចក្តីបុច្ឆានោះៗ ។

៦- **អធិករណវារ** សម្តែងពីសេចក្តីបុច្ឆាសួរអំពីសិក្ខាបទទាំងពួងដែលភិក្ខុប្រព្រឹត្តកន្លងហើយថា “អាបត្តិទាំងនោះ ដែលភិក្ខុត្រូវហើយនោះ ក្នុងអធិករណ៍ទាំង ៤ យ៉ាង នឹងហៅថា

អធិករណ៍អ្វី?” និងពាក្យវិសជ្ជនា ឆ្លើយតបតាមហេតុនៃសេចក្តីបុច្ឆានោះ ៗ។

**៧- សមថវារ** សម្តែងពីសេចក្តីបុច្ឆាសួរអំពីធម៌សម្រាប់រម្ងាប់នូវអាបត្តិ ដែលភិក្ខុត្រូវហើយថា “ក្នុងអធិករណសមថៈ ៧ យ៉ាង នឹងត្រូវរម្ងាប់ដោយអធិករណសមថៈណាខ្លះ?” និងពាក្យវិសជ្ជនា ឆ្លើយតបតាមហេតុនៃសេចក្តីបុច្ឆានោះ ៗ។

**៨- សមុច្ចយវារ** សម្តែងពីសេចក្តីបុច្ឆា និងវិសជ្ជនារួបរួមសេចក្តីក្នុងវារៈទាំង ៧ ប្រការ មានកត្ថបញ្ញត្តិវារៈជាដើម ដូចសេចក្តីដែលបានសម្តែងមកហើយនោះ ប្រមូលបញ្ចូលជាមួយគ្នាដោយសព្វគ្រប់ក្នុងវារៈនេះ។

មានវារៈ ៨ ប្រការទៀតមានឈ្មោះ និងសេចក្តីដូចគ្នានឹងវារៈទាំង ៨ ប្រការខាងដើមទៀត ព្រះគន្ថរបនាចារ្យលោកសម្តែងជានិគមវចនៈផ្ទួនឡើងទៀត ដើម្បីឱ្យជាការមាំរួបរួមផ្សំបូលគ្នានឹងវារៈ ៨ ប្រការខាងដើម ត្រូវជា ១៦ ប្រការ ហៅថា “សោឡសមហាវារៈ” ។

# វត្ថុ ១០ ប្រការ

នឹងសម្តែងអំពីវត្ថុ ១០ ប្រការ ដែលភិក្ខុទាំងឡាយនៅក្នុងដែនវជ្ជីហៅថា "វជ្ជីបុត្តកភិក្ខុ" សម្តែងឡើង, ដូចមានសេចក្តីដែលបានសម្តែងហើយក្នុងសត្តសតិកក្ខន្ធទី ២២ ខាងដើមនោះ, ជាសេចក្តីសង្ខេប ដើម្បីជាផ្លូវពិចារណានៃកុលបុត្រអ្នកសិក្សាទាំងឡាយ ។ វត្ថុ ១០ ប្រការនោះដូច្នេះ ៖

១- **កប្បតិ សិង្គិលោណកប្បោ វិនយប្បញ្ញត្តិ** ក្នុងសន្និធិការកសិក្ខាបទក្នុងសុត្តវិភង្គថា "របស់ជាយាវកាលិក បើភិក្ខុបានទទួលប្រគេនហើយទុកឱ្យកន្លងរាត្រី យកមកឆាន់ ត្រូវបាចិត្តិយ:" ។ ពួកវជ្ជីបុត្តកភិក្ខុសម្តែងឡើងថា "អំបិលដែលដាក់ទុកក្នុងក្លាក់ស្នែង បើទុកឱ្យកន្លងរាត្រីហើយយកមកឆាន់ ជាមួយនឹងអាហារបិណ្ឌបាតដែលសាបបាន មិនត្រូវអាបត្តិឡើយ " ។

២- **កប្បតិ ទ្វង្គុលកប្បោ វិនយប្បញ្ញត្តិ** ក្នុងវិកាលភោជនសិក្ខាបទក្នុងសត្តវិភង្គថា "ភិក្ខុឆាន់របស់ជាយាវកាលិកក្នុងវេលាវិកាល ត្រូវបាចិត្តិយ:" ។ ពួកវជ្ជីបុត្តកភិក្ខុសម្តែងឡើងថា

“បើព្រះអាទិត្យជ្រេទៅហើយ ប្រមាណពីរធ្នាប់ ក៏គួរនឹងឆាន់របស់ជាយាវកាលិកបាន មិនត្រូវអាបត្តិឡើយ” ។

៣- **កប្បតិ គាមន្តរកប្បោ វិនយប្បញ្ញត្តិ** ក្នុងបឋមបវារណាសិក្ខាបទក្នុងសុត្តវិភង្គថា “ ភិក្ខុឃាមភោជនហើយ ក្រោកបាកទីនោះហើយ ទៅឆាន់អនតិរិត្តភោជន ត្រូវបាចិត្តិយៈ” ។ ពួកវជ្ជីបុត្តកភិក្ខុ សម្តែងឡើងថា “បើមានសេចក្តីគិតថាអញនឹងចូលទៅកាន់ស្រុក, ដូច្នេះ ក៏ត្រូវឆាន់អនតិរិត្តភោជនបាន មិនត្រូវអាបត្តិឡើយ” ។

៤- **កប្បតិ អាវាសកប្បោ វិនយប្បញ្ញត្តិ** ក្នុងឧបោសថក្ខន្ធកទី ២ ក្នុងខន្ធកវិន័យថា “ទីអាវាស ដែលនៅក្នុងសីមាជាមួយគ្នា ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួង មានឧបោសថកម្មជាដើម ផ្សេងគ្នាមិនគួរ, បើធ្វើដូច្នោះ ត្រូវអាបត្តិទុក្កដ, កម្មដែលធ្វើនោះសោត ក៏មិនមែនជាសង្ឃកម្មឡើយ” ។ ពួកវជ្ជីបុត្តកភិក្ខុសម្តែងឡើងថា “ត្រូវធ្វើបានឥតមានទាស់ឡើយ ។

៥- **កប្បតិ អនុមតិកប្បោ វិនយប្បញ្ញត្តិ** ក្នុងចម្បេយ្យក្ខន្ធកទី ៩ ក្នុងខន្ធកវិន័យថា ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួង ត្រូវប្រជុំ

ភិក្ខុដែលមាននៅក្នុងសីមាជាមួយគ្នា ឱ្យមកប្រជុំព្រមជាប់ហត្ថ-បាសគ្នា ឬបាននាំឆន្ទបារិសុទ្ធនៃភិក្ខុដែលមានកិច្ចធុរៈ មិនបានមកកាន់ហត្ថបាសនោះទើបធ្វើបាន, បើមិនធ្វើដូច្នេះ ហៅថាធ្វើកម្មជាពួក, ត្រូវអាបត្តិទុក្កដ, កម្មដែលធ្វើនោះសោត ក៏មិនមែនជាសង្ឃកម្មឡើយ" ។ ពួកវជ្ជីបុត្តកភិក្ខុសម្តែងឡើងថា "មិនចាំបាច់មកជួបជុំគ្នាដូច្នោះទេ, បើមកដល់មុននឹងធ្វើសង្ឃកម្មមុនបណ្តើរទៅក៏បាន ឥតមានទាស់ឡើយ" ។

៦- **កប្បតិ អាចិណ្ណកប្បោ** ព្រះធម៌វិន័យពុទ្ធសាសនានេះមានរបៀបរៀបរៀងជាខ្នាតជាបន្ទាត់កំណត់ទុកថា ខុសថាត្រូវមកជាស្រេចហើយ សេចក្តីប្រតិបត្តិជាចរិត របស់ឧបជ្ឈាយ៍អាចារ្យតៗមក, បើត្រូវសមតាមរបៀបធម៌វិន័យនោះ ទើបឱ្យសិស្សានុសិស្សទាំងពួងប្រតិបត្តិតាម, បើមិនត្រូវមិនសមតាមរបៀបធម៌វិន័យទេ នោះសិស្សានុសិស្សទាំងពួង មិនត្រូវប្រ-តិបត្តិតាមឡើយ ។ ពួកវជ្ជីបុត្តកភិក្ខុសម្តែងឡើងថា "សេចក្តីប្រតិបត្តិជាចរិតទំនៀមទម្លាប់ របស់ឧបជ្ឈាយ៍អាចារ្យ ទោះ

ខុសក្តី ត្រូវក្តី សិស្សានុសិស្សទាំងពួងត្រូវប្រតិបត្តិតាម គត មានទាស់ឡើយ" ។

**៧- កប្បតិ អមថិតកប្បោ** ទឹកដោះស្រស់ដែលប្រែបាក ភាពដើមហើយ តែនៅមិនទាន់ក្លាយទៅជាទធិនៅឡើយ មាន វិនយប្បញ្ញត្តិថា "ភិក្ខុ ហាមភោជនហើយក្រោកបាកទីនោះ ហើយឆាន់ទឹកដោះជាអនតិរិត្តនោះ, ត្រូវអាបត្តិបាចិត្តិយៈ (តាម ន័យក្នុងបឋមបវារណាសិក្ខាបទ) ។ ពួកវជ្ជីបុត្តកភិក្ខុសម្តែង ឡើងថា "ឆាន់បានមិនត្រូវអាបត្តិឡើយ" ។

**៨- កប្បតិ ជឡោគឹ បាតុំ តរុណសុរា** គឺ សុរាដែលគេ ដាក់គ្រឿងស្រវឹងផ្សំត្រាំជាមួយគ្នាហើយ តែនៅខ្សោយមិនទាន់ ពេញជាទឹកស្រវឹងនៅឡើយ បើភិក្ខុផឹក ត្រូវអាបត្តិបាចិត្តិយៈ (តាមន័យក្នុងសុរាបានសិក្ខាបទក្នុងសុត្តវិភង្គ) ។ ពួកវជ្ជីបុត្តក-ភិក្ខុសម្តែងឡើងថា "តរុណសុរានោះ ភិក្ខុត្រូវផឹកបាន មិន ត្រូវអាបត្តិឡើយ " ។

៩- **កប្បតិ អទសកំ និសីទនំ វិនយប្បញ្ញត្តិ** ក្នុងនិសីទន-សិក្ខាបទក្នុងសុត្តវិភង្គថា "ភិក្ខុនឹងធ្វើសំពត់និសីទនៈ ត្រូវធ្វើឱ្យមានជាយ, បើមិនធ្វើដូច្នោះ ត្រូវអាបត្តិបាចិត្តិយៈ" ។ ពួកវជ្ជី-បុត្តកភិក្ខុសម្តែងឡើងថា "មិនបាច់ធ្វើឱ្យមានជាយ ក៏ត្រូវប្រើបាន មិនត្រូវអាបត្តិឡើយ" ។

១០- **កប្បតិ ជាតរូបរជតំ វិនយប្បញ្ញត្តិ** ក្នុងរូបិយសិក្ខាបទក្នុងសុត្តវិភង្គថា "ភិក្ខុមិនត្រូវទទួល មិនត្រូវត្រេកអរ បំពោះមាសប្រាក់ បើទទួល ឬត្រេកអរ ត្រូវនិស្សគ្គិយបាចិត្តិយៈ" ។ តែក្នុងមេណ្ឌកប្បញ្ញត្តិក្នុងភេសជ្ជក្ខន្ធកទី ៦ ក្នុងខន្ធកវិន័យមានពុទ្ធានុញ្ញាត ឱ្យភិក្ខុត្រេកអរ បំពោះបតុប្បច្ច័យដែលកើតអំពីរូបិយៈ គឺមាស ឬប្រាក់នោះបាន ប៉ុន្តែមានបញ្ញត្តិហាមមិនឱ្យទទួល មិនឱ្យត្រេកអរបំពោះត្រង់មាសប្រាក់ឡើយ ។ ពួកវជ្ជី-បុត្តកភិក្ខុសម្តែងឡើងថា "ភិក្ខុគួរទទួល ទាំងគួរត្រេកអរបំពោះត្រង់មាសប្រាក់នោះបាន មិនត្រូវអាបត្តិឡើយ" ។

វជ្ជីបុត្តកភិក្ខុទាំងឡាយ សម្តែងនូវវត្ថុខុសទាំង ១០ ប្រការនេះឡើងកាលណា ក៏កើតជាមន្ទិល ក្នុងព្រះពុទ្ធសាស-

ឆមណ្ឌល ជាហេតុនាំឱ្យកើតរវល់ធំ ដល់ព្រះអរហន្តទាំង-ឡាយៗ លោកក៏ប្រជុំគ្នា ធ្វើទុតិយសង្គាយនា ផ្ទៀងផ្ទាត់ធម៌-វិន័យសម្រេចសេចក្ដីថា វត្ថុទាំង ១០ ប្រការ ជាផ្លូវប្រតិបត្តិខុសអំពីរបៀបព្រះពុទ្ធសាសនា ជាស្រេច អំពីកាលនោះមកហើយ ។ ពុទ្ធសាសនិកជនទាំងឡាយ មិនត្រូវប្រតិបត្តិតាមលទ្ធិរបស់វជ្ជីបុត្តកភិក្ខុទាំងឡាយនោះឡើយ ។

**ចប់បាតិមោក្ខសង្ខេប**